៣០៧- លោក ហុង ប៊ូ	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣០៨- លោក សុខ ឆាយ	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣០៩- លោក ឯល ង៉ាន្លី	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣១០- លោកស្រី ង៉ែត សុជាតិ	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣១១- លោក គី ណាប	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣១២- លោកស្រី កៅ ឆេងសាង	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣១៣- លោកស្រី កឹម ឡងឌី	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣១៤- លោក ឆូច កន្ធាល់	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣១៥- លោក ឆាន មុន្នីសេដ្ឋា	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣១៦- លោក ឃូ ស៊ុនឡុង	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣១៧- លោក ឆាង ឃូ	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣១៨- លោក កល សាវុធ	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣១៩- លោក សុខ ធី	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣២០- លោកស្រី ជា គីមអៀង	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦

៣២១- លោកស្រី **ហោ ម៉ាលី**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣២២- លោកស្រី **ង៉ាយ ង៉ាឌី**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣២៣- លោក **ហាច់ ភៅ**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣២៤- លោកស្រី **អ៊ុច ង៉ាន់នី**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣២៥- លោកស្រី **អ៊ឹង ឥណ្ណគន្ធារី**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣២៦- លោកស្រី **ឆេង ឆាណាគីរម្យ**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣២៧- លោក **ឆាក់ សុផ្ឆា**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣២៨- លោក **ឆួច ម៉ៅច**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣២៩- លោក **ឧប គុណ**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៣០- លោក **ជុំ ឈុន្លី**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៣១- លោក **សុខ គណ្ណារិទ្ធិ**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៣២- លោកស្រី **ស៊ឹម សាមិនី**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៣៣- លោកស្រី **ឆន សុធារី**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៣៤- លោក **លឹម ឆាវី**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៣៥- លោកស្រី **សែម សុភណ្ណា**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦

៣៣៦- លោកស្រី ស្រ្តី សុីឡូឡា	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៣៧- លោកស្រី គង់ រ៉ានី	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៣៨- លោក ឡេវ ម៉ូលីណា	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៣៩- លោក ត្រី ណារិទ្ធ	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៤០- លោកស្រី ឃឹម ង៉ារី	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៤១- លោកស្រី យិត ឌុតសានី	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៤២- លោក រស់ ឃុរិទ្ធ	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៤៣- លោក ភាន់ គីមអេង	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៤៤- លោក ស៊ុក សីហា	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៤៥- លោកស្រី សេង សត្យា	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៤៦- លោកស្រី ហោង អេង	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៤៧- លោក ជា អម្ពរ	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៤៨- លោក មែរ ច័ន្ទតីរ៉ែត	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៤៩- លោក ឆូ ប៊ុច	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៥០- លោក កែវ គុយហោង	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦

៣៥១- លោក **ចាប សុខលី**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៥២- លោកស្រី **កែវ លក្ខិណា**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៥៣- លោក **លន់ ស៊ីនន់**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៥៤- លោក **អ៊ូ សាម៉ៅ**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៥៥- លោក **រ៉ូ ឆេង សៃ**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៥៦- លោកស្រី **ឱក ឆិមល**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៥៧- លោក **ប៉ែន ម៉ែនសៃ**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៥៨- លោក **គីម ចុនធី**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៥៩- លោក **គាត ជីម**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៦០- លោក **ជា ចាន់ហោង**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៦១- លោក **ប៉ាង ឥសុទ្ធ**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៦២- លោក **ហៀង សុខេង**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៦៣- លោក **អ៊ុក ឥណ្ណា**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៦៤- លោក **ព្រឿង ធីរិទ្ធ**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦

៣៦៥- លោកស្រី **ហ៊ី សុភណ្ណលក្ខិណា**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៦៦- លោក **សេង សុភណ្ណារស្មី**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៦៧- លោកស្រី **លី រីណា**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៦៨- លោក **លី ណៃពីន**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៦៩- លោក **ហោ សំណៀ**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៧០- លោកស្រី **កែវ កិច្ចស៊ុន**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៧១- លោក **ចៅ ឌីរយុទ្ធ**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៧២- លោក **សាំង សារ៉ែត**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៧៣- លោក **អ៊ូច ចាន់ណារិទ្ធ**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៧៤- លោក **គី ឃួឈាង**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៧៥- លោក **ឆាយ សុចលី**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦
៣៧៦- លោកស្រី **ប៉ក់ យ៉ារី**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦

មាត្រា ២ : ប្តូរ និងតម្លើងប្រភេទក្របខ័ណ្ឌ ដល់មន្ត្រីរាជការ ០៣ រូប នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម នៅក្រសួងអប់រំ យុវជន និងកីឡា ចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៦ ៖

១- លោក **ឡាយ ឃូ**	ពីគ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែពិសេស ថ្នាក់លេខ ១ មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៥

២- លោក **ភៅ ថាវរ:**	ពីគ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែពិសេស ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៥
៣- លោក **ឌី សំអឿន**	ពីគ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែពិសេស ថ្នាក់លេខ ១
	មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៥

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុក អនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ជាការ
នរោត្តម សីហមុនី

ពារណ. ១៧០៤.០៨៧

លេខ: ៨៥. ស.ណ

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ កុម្ភ: ឆ្នាំ ២០១៧

សំណៅជែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភ: ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

- លេខ : ២៦៣/០០១/២០១៧
ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧
- លេខ : ២៦៤/០០២/២០១៧
ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧

សេចក្តីសម្រេច

លេខ : ១៦១/០០១/២០១៧ កបធ.ច
ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៧

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ ០០៦ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលតម្កល់សេចក្តីសម្រេចលេខ ០១/០១៧ ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាប្រជុំសម្រេច សង្កាត់លេខ១ ក្រុងព្រះសីហនុ តែបដិសេធ ០២នាក់ ក្នុងចំណោម ៤១នាក់ ដែលមិនមានឈ្មោះក្នុងបញ្ជីបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ០០៧ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលតម្កល់សេចក្តីសម្រេចលេខ ០១ ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០១៧

របស់ក្រុមប្រឹក្សាប្រជុំសម្រេច សង្កាត់លេខ២ ក្រុងព្រះសីហនុ តែបដិសេធ ១២នាក់ ក្នុងចំណោម ៣៥នាក់ ដែលមិនមានឈ្មោះក្នុងបញ្ជីបោះឆ្នោត

- បានឃើញលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៧ របស់លោក **សឿន ធី** ជូនលោកមេធាវី **ផែង ហោង** ដើម្បីធ្វើជាមេធាវីតំណាងក្នុងការប្តឹងជំទាស់នឹងសេចក្តីសម្រេច លេខ ០០៦ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៧ របស់លោក **តុំ អ៊ួន** ជូនលោកមេធាវី **ផែង ហោង** ដើម្បីធ្វើជាមេធាវីតំណាងក្នុងការប្តឹងជំទាស់នឹងសេចក្តីសម្រេច លេខ ០០៧ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតលេខ ០៧៨ គ.ជ.ប ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧទ្ទេសនាមឯកឧត្តម **ហាន សុធិ** ដើម្បីមកបំភ្លឺលើពាក្យបណ្តឹងរបស់លោកមេធាវី **ផែង ហោង**
- បានឃើញលិខិតលេខ ០៨៩ គ.ជ.ប ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧទ្ទេសនាមឯកឧត្តម **ឆេង ឥទ្ធា** និងឯកឧត្តម **សំ សាវុធ** ដើម្បីមកបំភ្លឺលើពាក្យបណ្តឹងរបស់លោកមេធាវី **ផែង ហោង**
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៧ របស់លោកមេធាវី **ផែង ហោង** តំណាងដោយអាណត្តិឲ្យលោក **សឿន ធី** និង លោក **តុំ អ៊ួន** ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០០៦ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ និង លេខ ០០៧ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ របស់គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោកមេធាវី **ផែង ហោង** កាលពីថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១៧ ចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញកំណត់ហេតុបំភ្លឺរបស់ឯកឧត្តម **ហាន សុធិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត ចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១៧ ដោយភ្ជាប់សារណាចំនួន ០២ ច្បាប់ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១៧ និងឯកសារពាក់ព័ន្ធនឹងប្រជាពលរដ្ឋ ចំនួន ៧៦នាក់ ដែលត្រូវបានប្តឹងថាជាជនជាតិបរទេស (វៀតណាម)
- បានឃើញកំណត់ហេតុចុះស៊ើបអង្កេតនៅសង្កាត់លេខ១ និងសង្កាត់លេខ២ នៅក្រុងព្រះសីហនុ របស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៧

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានស្តាប់ការឆ្លើយបំភ្លឺរបស់លោកមេធាវី ផែង ហោង

ក្រោយពីបានស្តាប់ការបំភ្លឺរបស់តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៧ របស់លោកមេធាវី **ផែង ហោង** ស្ថិតក្នុងដំណាក់កាលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។ យោងតាមមាត្រា ៦២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង មាត្រា ២៦ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បណ្តឹងនេះធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកមកពិនិត្យបាន
- យល់ឃើញថា នៅពេលឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជានៅពេលសវនាការជំនុំជម្រះជាសាធារណៈ លោកមេធាវី **ផែង ហោង** បានបញ្ជាក់ដូចតទៅ :

• លោកជាមេធាវីតំណាងឲ្យដើមបណ្តឹង **សឿន ធី** និង **តុំ ង៉ែន** ដែលប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសង្កាត់លេខ ១ និង សង្កាត់លេខ ២ ក្រុងព្រះសីហនុ និងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីធ្វើការប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ សុំលុបឈ្មោះពីបញ្ជីបោះឆ្នោតចំនួន ៤១នាក់ ដែលជាបណ្តឹងរបស់លោក **សឿន ធី** និងសុំលុបឈ្មោះពីបញ្ជីបោះឆ្នោតចំនួន ៣៥នាក់ ដែលជាបណ្តឹងរបស់លោក **តុំ ង៉ែន** ។

• ទាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទាំងក្រុមប្រឹក្សាសង្កាត់ បានប្រគល់ឲ្យលោកតែសម្រង់សេចក្តីសម្រេចទម្រង់ ១២០៣ តែប៉ុណ្ណោះ ។

• ក្នុងបណ្តឹង កូនក្តីរបស់លោកបានកត់តែឈ្មោះជនដែលគាត់សង្ស័យ ហើយសុំលុបពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ដោយមិនមានបញ្ជីឈ្មោះបោះឆ្នោតផ្លូវការ ឆ្នាំ២០១៦ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទេ ។

• លោកជាមេធាវីដែលមានសិទ្ធិតំណាងឲ្យដើមបណ្តឹងមិនស្គាល់អត្តសញ្ញាណអ្នកដែលត្រូវសុំលុបឈ្មោះនោះទេ ប៉ុន្តែកូនក្តីរបស់លោកដែលរស់នៅមូលដ្ឋានគាត់ដឹងច្បាស់ទើបគាត់ហ៊ានប្តឹង ដោយទទួលស្គាល់ថា អ្នកទាំងនោះមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

• សំណូមពរ ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យសុចរិតភាពនៃការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។ បើជនបរទេសទាំងនោះ បានទទួលអត្តសញ្ញាណប័ណ្ណដោយទុច្ចរិត លោកសូមឲ្យក្រុមប្រឹក្សាធម្មនុញ្ញលុបឈ្មោះជនបរទេសទាំងនោះតាមបណ្តឹងរបស់កូនក្តីលោក ។

- យល់ឃើញថា នៅចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្តម **ហាន សុធិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបំភ្លឺដូចតទៅ :

• លោកមេធាវី **ផែង ហោង** តំណាងដោយអាណាព្តិឲ្យឈ្មោះ **សឿន ធី** និង ឈ្មោះ **តុំ ង៉ែន** ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០០៦ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលរក្សាទុកឈ្មោះប្រជាពលរដ្ឋចំនួន ៤១ នាក់ ក្នុងបញ្ជីបោះឆ្នោត និងសេចក្តីសម្រេចលេខ ០០៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលរក្សាទុកឈ្មោះប្រជាពលរដ្ឋចំនួន ៣៥ នាក់ ក្នុងបញ្ជីបោះឆ្នោត ។

• នៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លោកមេធាវី **ផែង ហេង** ប្តឹងថា ប្រជាពលរដ្ឋទាំងនោះ ជាជនជាតិរៀតណាមដោយពុំមានឯកសារភស្តុតាងបញ្ជាក់ច្បាស់លាស់ឡើយ ក្រៅពីសំអាងថា និយាយភាសាខ្មែរមិនច្បាស់ និងមិនមានព្រះរាជក្រឹត្យស្តីពីការផ្តល់សញ្ជាតិ ។

• ក្នុងសេចក្តីសម្រេចលេខ ០០៦ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតបានបដិសេធប្រជាពលរដ្ឋចំនួន ០២នាក់ ក្នុងចំណោម ៤១នាក់ ដោយគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។ ហើយក្នុងសេចក្តីសម្រេចលេខ ០០៧ របស់គណៈកម្មាធិ-ការជាតិរៀបចំការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបដិសេធប្រជាពលរដ្ឋចំនួន ១២នាក់ ក្នុងចំណោម ៣៥នាក់ ដោយគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។

• ការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ០០៦ និងលេខ ០០៧ គឺផ្អែកលើមាត្រា ៤៦ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

• សំណូមពរ សូមឲ្យក្រុមប្រឹក្សាធម្មនុញ្ញ តម្កល់សេចក្តីសម្រេចលេខ ០០៦ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ និងសេចក្តីសម្រេចលេខ ០០៧ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ របស់គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល

• គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានជូនសារណាចំនួន ០២ ច្បាប់ ពាក់ព័ន្ធនឹងបណ្តឹងទាំងពីរនេះ ។

- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ ឯកឧត្តម **ឆេព ឌីថា** និងឯកឧត្តម **សំ សាវុធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបំភ្លឺដូចមតិឯកឧត្តម **មាន សធិ** ដែរ។
- យល់ឃើញថា លោកមេធាវី **ផែង ហេង** ដែលបានប្តឹងជំទាស់សេចក្តីសម្រេចលេខ ០០៦ និងលេខ ០០៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងការសុំលុបឈ្មោះជនជាតិបរទេស (រៀតណាម) ពុំមានឯកសារ ឬ ភស្តុតាងជាលាយលក្ខណ៍អក្សរដែលអាចឲ្យក្រុមប្រឹក្សាធម្មនុញ្ញ បដិសេធសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងពីរនេះបានឡើយ
- យល់ឃើញថា តាមការចុះស៊ើបអង្កេតរបស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ប្រជាពលរដ្ឋដែលត្រូវលោកមេធាវី **ផែង ហេង** ប្តឹង សុទ្ធតែបានបំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោត គ្រប់គ្រាន់តាមច្បាប់ បទបញ្ជា និង នីតិវិធីចុះឈ្មោះបោះឆ្នោត
- យល់ឃើញថា សេចក្តីសម្រេចលេខ ០០៦ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ និង សេចក្តីសម្រេចលេខ ០០៧ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានមូលដ្ឋានគតិយុត្តត្រឹមត្រូវ
- យល់ឃើញថា ការបញ្ជាក់អំពីធាតុពិតនៃអត្តសញ្ញាណរបស់បុគ្គលណាម្នាក់ មិនមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ។

សម្រេច

ចំពោះមុខដើមបណ្តឹង និងចំពោះមុខតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

មាត្រា ១- ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៧ របស់លោកមេធាវី **ផែង ហេង** តំណាងដោយអាណត្តិឲ្យលោក **សៀន ធី** និង លោក **តុំ រ៉ូន** ភ្នាក់ងារគណបក្សសង្គ្រោះជាតិ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

មាត្រា ២- តម្កល់សេចក្តីសម្រេចលេខ ០០៦ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ និង សេចក្តីសម្រេចលេខ ០០៧ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

មាត្រា ៣- សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៧ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៧

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និងជាក្រុមប្រឹក្សាជំនុំជម្រះ

ប្រធាន

អ៊ឹម ឈុនលឹម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមហ៊ុនមេធាវីប៊ីប៊ីស៊ី
BBC LAW FIRM
BARRISTER AND BUSINESS CONSULTANT

ក្រុមហ៊ុនមេធាវីប៊ីប៊ីស៊ី
លេខ 263/001/2017
ថ្ងៃ 22-មករា-2017
បញ្ជូន ម៉ោង 15:08:25

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ០១ ឆ្នាំ២០១៧

ពាក្យបណ្តឹង

ខ្ញុំបាទមេធាវី **ផែង ហោង** ការិយាល័យផ្ទះលេខ១៤CE, ផ្លូវ៣៨៤ ភូមិ០៥ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរសព្ទ័លេខ០១២ ៨៥០ ២៨២ ជាមេធាវីតំណាងឱ្យឈ្មោះ **សឿន ធី** កេទប្រុស ថ្ងៃខែឆ្នាំកំណើត០៣-០២-១៩៧៦ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះ ភូមិ២ សង្កាត់លេខ៣ ខណ្ឌព្រះសីហនុ ខេត្តព្រះសីហនុ។

សូមគោរពជូន
ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

កម្មវត្ថុ៖ ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ០០៦ គជប. ចុះថ្ងៃទី១៦/០១/ ឆ្នាំ២០១៧ របស់ គ.ជ.ប ដែលមិនបានលុបឈ្មោះជនជាតិបរទេស(វៀតណាម)ចំនួន៤១នាក់ ចេញពីបញ្ជីឈ្មោះបោះដំបូងឆ្នោត ឆ្នាំ២០១៦។

យោង៖ - លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី០៩/០១/២០១៧ របស់កូនក្តីឈ្មោះ សឿន ធី
- សេចក្តីសម្រេចលេខ០០៦ ចុះថ្ងៃទី១៦/០១/២០១៧ របស់គជប។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា កូនក្តីខ្ញុំ កើតទុក្ខមិនសុខចិត្តនឹងការសម្រេចរបស់ គ.ជ.ប ដែលមិនបានលុបឈ្មោះជនជាតិបរទេស(វៀតណាម) ចំនួន៤១នាក់ចេញពីបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៦។ ការដែលកូនក្តីខ្ញុំបានប្តឹងឱ្យលុបឈ្មោះជនជាតិបរទេសទាំងនេះដោយសារ ជនទាំងនេះ និយាយខ្មែរមិនច្បាស់ និងអ្នកខ្លះ ឪពុកម្តាយជាជនជាតិវៀតណាមមិនដែលធ្លាប់បានធ្វើសញ្ជាតិតូបនីយកម្មម្តងណាឡើយ ហើយការសម្រេចសេចក្តីរបស់គជប ក៏មិនបានឱ្យជនចុងចម្លើយមកចូលរួមដេញដោរការពារខ្លួននៅចំពោះមុខអង្គសវនាការដែរ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងសម្រេច តាមនីតិវិធី ដោយអនុគ្រោះ។

សូម **ឯកឧត្តម** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ ពីខ្ញុំ។

អាសយដ្ឋាន: ការិយាល័យផ្ទះ ១៤CE₀ ផ្លូវ ៣៨៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ
Tel: (855)-12 850 282 / (855)-81 850 282, Email: lawfirmbbc@gmail.com, Blog: bbclawfirm.blogspot.com

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



BBC
BARRISTER AND BUSINESS CONSULTANT
LAW FIRM
ក្រុមហ៊ុនមេធាវីប៊ីប៊ីស៊ី

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ០១ ឆ្នាំ២០១៧

ពាក្យបណ្តឹង

ខ្ញុំបាទមេធាវី **ផែង ហោង** ការិយាល័យផ្ទះលេខ១៤CE, ផ្លូវ៣៨៤ ភូមិ០៥ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរសព្ទ័លេខ០១២ ៨៥០ ២៨២ ជាមេធាវីតំណាងឱ្យឈ្មោះ **កុំ អ៊ួន** ភេទប្រុស ថ្ងៃខែឆ្នាំកំណើត១៦-០៤-១៩៧៥ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះ ភូមិ១ សង្កាត់លេខ២ ខណ្ឌព្រះសីហនុ ខេត្តព្រះសីហនុ។

សូមគោរពជូន
ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

កម្មវត្ថុ៖ ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ០០៧ គជប. ចុះថ្ងៃទី១៦/០១/ ឆ្នាំ២០១៧ របស់ គ.ជ.ប ដែលមិនលុបឈ្មោះជនជាតិបរទេស(វៀតណាម)ចំនួន៣៥នាក់ ចេញពីបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៦។

យោង៖ - លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី០៩/០១/២០១៧ របស់កូនក្តីឈ្មោះ កុំ អ៊ួន។
- សេចក្តីសម្រេចលេខ០០៧ ចុះថ្ងៃទី១៦/០១/២០១៧ របស់គជប។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា កូនក្តីខ្ញុំ កើតទុក្ខមិនសុខចិត្តនឹងការសម្រេចរបស់ គ.ជ.ប ដែលមិនបានលុបឈ្មោះជនជាតិបរទេស(វៀតណាម) ចំនួន៣៥នាក់ ចេញពីបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៦។ ការដែលកូនក្តីខ្ញុំបានប្តឹងឱ្យលុបឈ្មោះជនជាតិបរទេសទាំងនេះដោយសារជនទាំងនេះ និយាយខ្មែរមិនច្បាស់ និងអ្នកខ្លះ ឪពុកម្តាយជាជនជាតិវៀតណាមមិនដែលធ្លាប់បានធ្វើសញ្ជាតិតូបនីយកម្មម្តងណាឡើយហើយការសម្រេចសេចក្តីរបស់គជប ក៏មិនបានឱ្យជនចុងចម្លើយមកចូលរួមដេញដោលការពារខ្លួនចំពោះមុខអង្គសវនាការដែរ។ តែការសម្រេចចុងក្រោយរបស់គជប គឺរក្សាទុកឈ្មោះចំនួន៣៥នាក់ក្នុងបញ្ជីបោះឆ្នោតនៅដដែលដោយពុំមានសំអាងហេតុឱ្យបានច្បាស់លាស់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងសម្រេច តាមនីតិវិធី ដោយអនុគ្រោះ។

សូម **ឯកឧត្តម** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ ពីខ្ញុំ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

- លេខ : ២៦៥/០០៣/២០១៧
  ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧
- លេខ : ២៦៦/០០៤/២០១៧
  ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧
- លេខ : ២៦៧/០០៥/២០១៧
  ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧
- លេខ : ២៦៨/០០៦/២០១៧
  ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧
- លេខ : ២៦៩/០០៧/២០១៧
  ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧
- លេខ : ២៧០/០០៨/២០១៧
  ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧

សេចក្តីសម្រេច

លេខ : ១៦២/០០២/២០១៧ កបធ.ច
ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៧

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ ០០២ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញសេចក្តីសម្រេចលេខ ០០៨ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ០០៩ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ០១៤ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ០១៧ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ០២០ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតប្រគល់សិទ្ធិចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់លោកស្រី **ឡៀង សម្បត្តិម៉ូនី** ជូនលោក **ភាក់ កុម្ភារ** ក្នុងការដាក់ពាក្យប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០០២ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧
- បានឃើញលិខិតប្រគល់សិទ្ធិចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់លោក **សាន់ ប៊ុណ្ណាយ៉ុង** ជូនលោក **ភាក់ កុម្ភារ** ក្នុងការដាក់ពាក្យប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០០៨ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧
- បានឃើញលិខិតប្រគល់សិទ្ធិចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់លោក **ឈឹម សុខពៅ** ជូនលោក **ភាក់ កុម្ភារ** ក្នុងការដាក់ពាក្យប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០០៩ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧
- បានឃើញលិខិតប្រគល់សិទ្ធិចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់លោក **ហ៊ាង ចិន្តា** ជូនលោក **ភាក់ កុម្ភារ** ក្នុងការដាក់ពាក្យប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០១៤ លេខ ០១៧ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧ និង លេខ ០២០ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០១៧
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់លោក **ភាក់ កុម្ភារ** តំណាងឲ្យ លោកស្រី **ឡៀង សម្បត្តិម៉ូនី** លោក **សាន់ ប៊ុណ្ណាយ៉ុង** លោក **ឈឹម សុខពៅ** និងលោក **ហ៊ាង ចិន្តា** ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០០២ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ លេខ ០០៨ លេខ ០០៩ លេខ ០១៤ លេខ ០១៧ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧ និងលេខ ០២០ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **ភាក់ កុម្ភារ** កាលពីថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៧ ចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញលិខិតលេខ ០៧៦ គ.ជ.ប ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧទ្ទេសនាមឯកឧត្តម **ឯម សុជាត** និង ឯកឧត្តម **ម៉ៅ សុគារិទ្ធ** មកបំភ្លឺលើពាក្យបណ្តឹងទាំង ០៦ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់លោក **ភាក់ កុម្ភារ**
- បានឃើញកំណត់ហេតុបំភ្លឺរបស់ឯកឧត្តម **ឯម សុជាត** និង ឯកឧត្តម **ម៉ៅ សុគារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៧ ភ្ជាប់ដោយសារណា ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៧ និង ឯកសារពាក់ព័ន្ធនឹងប្រជាពលរដ្ឋ ៤៩២ នាក់ ដែលត្រូវបានប្តឹងថាជាជនបរទេស
- បានឃើញកំណត់ហេតុចុះស៊ើបអង្កេតរបស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ២៦ និងទី ២៧ ខែ មករា ឆ្នាំ២០១៧ នៅសង្កាត់ឫស្សីកែវ សង្កាត់គីឡូម៉ែត្រលេខ ៦ សង្កាត់ព្រែកប្រា សង្កាត់ច្បារអំពៅទី២
- បានឃើញលិខិតលេខ ០៩៣ គ.ជ.ប ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧទ្ទេសនាមឯកឧត្តម **ម៉ៅ សុគារិទ្ធ** និង លោក **តាង ទិចិត្រ** ចូលរួមសវនាការជាសាធារណៈ ដើម្បីបំភ្លឺលើពាក្យបណ្តឹងទាំង ០៦ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់លោក **ភាក់ កុម្ភារ**

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍
ក្រោយពីបានស្តាប់ការឆ្លើយបំភ្លឺរបស់ដើមបណ្តឹង
ក្រោយពីបានស្តាប់ការបំភ្លឺរបស់តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់លោក **ភាក់ កុម្ភារ** ទាំង០៦ ស្ថិតក្នុងដំណាក់កាលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។ យោងតាមមាត្រា ៦២នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងមាត្រា ២៦ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បណ្តឹងរបស់លោក **ភាក់ កុម្ភារ** បានធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកមកពិនិត្យបាន
- យល់ឃើញថា នៅពេលឆ្លើយបំភ្លឺនៅចំពោះ មុខក្រុមទី ២ នៃក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជានៅពេលសវនាការជំនុំជម្រះជាសាធារណៈ លោក **ភាក់ កុម្ភារ** បានបញ្ជាក់ដូចខាងក្រោម៖
លោកមិនមានឯកសារអ្វីបន្ថែមទៅលើពាក្យបណ្តឹងទៀតទេ ការប្តឹងទាំងអស់នេះគ្រាន់តែជាការសង្ស័យថ្នាក់ក្រោមជូនព័ត៌មានទៅអាជ្ញាធរ ដោយសាររឿងបោះឆ្នោតគេធ្វើអីចឹង។ លោក **ភាក់ កុម្ភារ** បានកត់សម្គាល់ថា អ្នកមកចុះឈ្មោះបោះឆ្នោតទាំងនោះសុទ្ធតែមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ តែសំខាន់លោកស្នើឲ្យក្រុមប្រឹក្សាជំនុំជម្រះនៃក្រុមប្រឹក្សាធម្មនុញ្ញ ពិចារណាលើភាពត្រឹមត្រូវនៃការផ្តល់អត្តសញ្ញាណប័ណ្ណ និងសំណូមពរក្រុមប្រឹក្សាជំនុំជម្រះ សុំលុបឈ្មោះអ្នកទាំងនោះដដែល។

- យល់ឃើញថា នៅពេលបំភ្លឺចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជានៅពេលសវនាការជំនុំជម្រះជាសាធារណៈ តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបំភ្លឺដូចខាងក្រោម ៖

(១) លោក **ភាក់ កុម្ភារ** ដោយបានការផ្ទេរសិទ្ធិពីលោកស្រី **ឡៀង សម្បត្តិម៉ូនី** ភ្នាក់ងារគណបក្សសង្គ្រោះជាតិ បានដាក់ពាក្យបណ្តឹងជំទាស់នឹងសេចក្តីសម្រេច លេខ ០០២ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលរក្សាទុកឈ្មោះប្រជាពលរដ្ឋចំនួន ៣៨ នាក់ ក្នុងបញ្ជីបោះឆ្នោត នៅសង្កាត់ឫស្សីកែវ មកក្រុមប្រឹក្សាធម្មនុញ្ញ ។

(២) លោក **ភាក់ កុម្ភារ** ដោយបានការផ្ទេរសិទ្ធិពីលោក **សាន់ ច៊ុណ្ណយ៉ុង** ភ្នាក់ងារគណបក្សសង្គ្រោះជាតិ បានដាក់ពាក្យបណ្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០០៨ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលរក្សាទុកឈ្មោះប្រជាពលរដ្ឋចំនួន ៤៣ នាក់ ក្នុងបញ្ជីបោះឆ្នោត នៅសង្កាត់គីឡូម៉ែតលេខ៦ មកក្រុមប្រឹក្សាធម្មនុញ្ញ ។

(៣) លោក **ភាក់ កុម្ភារ** ដោយបានការផ្ទេរសិទ្ធិពីលោក **ឈឹម សុខពៅ** ភ្នាក់ងារគណបក្សសង្គ្រោះជាតិ បានដាក់ពាក្យបណ្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០០៩ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលរក្សាទុកឈ្មោះប្រជាពលរដ្ឋចំនួន ១៣១ នាក់ ក្នុងបញ្ជីបោះឆ្នោត នៅសង្កាត់ព្រែកប្រា មកក្រុមប្រឹក្សាធម្មនុញ្ញ ។

(៤) លោក **ភាក់ កុម្ភារ** ដោយបានការផ្ទេរសិទ្ធិពីលោក **ហ៊ាង ចិន្តា** ភ្នាក់ងារគណបក្សសង្គ្រោះជាតិ បានដាក់ពាក្យបណ្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០១៤ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលរក្សាទុកឈ្មោះប្រជាពលរដ្ឋចំនួន ០៤ នាក់ ក្នុងបញ្ជីបោះឆ្នោត នៅសង្កាត់ច្បារអំពៅទី២ មកក្រុមប្រឹក្សាធម្មនុញ្ញ ។

(៥) លោក **ភាក់ កុម្ភារ** ដោយបានការផ្ទេរសិទ្ធិពីលោក **ហ៊ាង ចិន្តា** ភ្នាក់ងារគណបក្សសង្គ្រោះជាតិ បានដាក់ពាក្យបណ្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០១៧ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលរក្សាទុកឈ្មោះប្រជាពលរដ្ឋចំនួន ១២៩ នាក់ ក្នុងបញ្ជីបោះឆ្នោត នៅសង្កាត់ច្បារអំពៅទី២ មកក្រុមប្រឹក្សាធម្មនុញ្ញ ។

(៦) លោក **ភាក់ កុម្ភារ** ដោយបានការផ្ទេរសិទ្ធិពីលោក **ហ៊ាង ចិន្តា** ភ្នាក់ងារគណបក្សសង្គ្រោះជាតិ បានដាក់ពាក្យបណ្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០២០ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលរក្សាទុកឈ្មោះប្រជាពលរដ្ឋចំនួន ១៤៧ នាក់ ក្នុងបញ្ជីបោះឆ្នោត នៅសង្កាត់ច្បារអំពៅទី២ មកក្រុមប្រឹក្សាធម្មនុញ្ញ ។

តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបំភ្លឺថា ដើមបណ្តឹងចោទប្រជាពលរដ្ឋទាំងនោះថាជាជនបរទេសប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរយកទៅចុះឈ្មោះបោះឆ្នោត និងសំអាងលើការនិយាយខ្មែរ ស្តាប់គ្នាមិនបាន លើការនិយាយស្តី ទំនាក់ទំនងសង្គម និង ទំនៀមទម្លាប់ប្រពៃណី ហើយពេលចូលឆ្នាំចិន ឬ វៀតណាម អ្នកទាំងនោះទៅស្រុករបស់គេអស់ រស់នៅតាមមាត់ទន្លេនៅក្នុងភូមិរបស់ខ្លួនកំពុងរស់នៅភាគច្រើននិយាយខ្មែរមិនច្បាស់ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ តែមិនមានព្រះរាជក្រឹត្យ មានសំនៀងនិយាយជាជនជាតិវៀតណាម មិនចេះសរសេរ មិនចេះ

អានអក្សរខ្មែរ មានសម្លៀកបំពាក់ជាជនជាតិវៀតណាម និង មានការរៀបចំសែនព្រេនជាជនជាតិវៀតណាម ។

តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបំភ្លឺថា ចំណែកឯកាគីខាងចុងចម្លើយអះអាងថា ខ្លួនមានស្រុកកំណើតច្បាស់លាស់នៅស្រុកខ្មែរ ហើយបានទៅចុះឈ្មោះបោះឆ្នោតប្រើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មានឯកសារសៀវភៅគ្រួសារ សំបុត្របញ្ជាក់កំណើត មានឯកសារបោះឆ្នោតតាំងពីសម័យអ៊ុនតាក់ បានបំពេញលក្ខខណ្ឌត្រឹមត្រូវតាមច្បាប់ និង បទបញ្ជា និងនីតិវិធីចុះឈ្មោះបោះឆ្នោត ។

ក្នុងចំណោមអ្នកដែលត្រូវគេប្តឹងចំនួន ៤៩២ នាក់ មាន ៤៨២ នាក់ ប្រើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរក្នុងការចុះឈ្មោះ និង ១០ នាក់ ប្រើឯកសារបញ្ជាក់អត្តសញ្ញាណក្នុងការចុះឈ្មោះ ។

តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបញ្ជាក់ថា ការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ផ្អែកលើ ៖

- មាត្រា ៥១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ចំណុច ខ និង ប្រការ ៤.៤ នៃបទបញ្ជា និង នីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦

- ការត្រួតពិនិត្យនិងស្រាវជ្រាវរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតតាមរយៈឯកសាររបស់ក្រុមចុះឈ្មោះបោះឆ្នោតសង្កាត់ បញ្ជូនមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយអ្នកទាំងនោះប្រើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និង បានចុះឈ្មោះបោះឆ្នោតនៅចំពោះមុខក្រុមចុះឈ្មោះបោះឆ្នោត

- ការកំណត់សញ្ជាតិរបស់បុគ្គលម្នាក់ៗ គេអាចសម្គាល់បានតាមរយៈលិខិតយថាភូតផ្លូវការចេញដោយអាជ្ញាធរមានសមត្ថកិច្ច

- ការធ្វើការស៊ើបអង្កេតលើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ តាមរយៈការចូលសញ្ជាគូបនីយកម្មជាសមត្ថកិច្ចរបស់តុលាការ និងអាជ្ញាធរមានសមត្ថកិច្ច

- យល់ឃើញថា លោក **ភាគ់ កុម្ភារ** ដើមបណ្តឹងដែលបានប្តឹងជំទាស់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងការសុំលុបឈ្មោះជនបរទេស ពុំមានឯកសារ ឬភស្តុតាងជាលាយលក្ខណ៍អក្សរដែលអាចឲ្យក្រុមប្រឹក្សាធម្មនុញ្ញបដិសេធសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឡើយ
- យល់ឃើញថា តាមការស៊ើបអង្កេតរបស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ប្រជាពលរដ្ឋដែលត្រូវដើមបណ្តឹងប្តឹង អ្នកទាំងនោះសុទ្ធតែបានបំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោតត្រឹមត្រូវតាមច្បាប់ បទបញ្ជា និង នីតិវិធីចុះឈ្មោះបោះឆ្នោត
- យល់ឃើញថា សេចក្តីសម្រេចលេខ០០២ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ លេខ០០៨ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ លេខ០០៩ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ លេខ០១៤ ចុះថ្ងៃទី១៧

ខែមករា ឆ្នាំ២០១៧ លេខ០១៧ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ និង លេខ០២០ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានមូលដ្ឋានគតិយុត្តត្រឹមត្រូវ - យល់ឃើញថា ការបញ្ជាក់អំពីធាតុពិតនៃអត្តសញ្ញាណរបស់បុគ្គលណាម្នាក់ មិនមែនជាសមត្ថកិច្ច របស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ។

សម្រេច

ចំពោះមុខដើមបណ្តឹង និង ចំពោះមុខតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

មាត្រា ១. ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់លោក **ភាក់ ភុម្មារ** តំណាងឲ្យ លោកស្រី **ឡៅ សម្បត្តិម៉ូនី** លោក **សាន់ ប៊ុណ្ណយ៉ុច** លោក **ឈឹម សុខពៅ** និង លោក **ហ៊ាង ចិន្តា** ភ្នាក់ងារគណបក្សសង្គ្រោះជាតិ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

មាត្រា ២. តម្កល់សេចក្តីសម្រេចលេខ ០០២ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ០០៨ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ០០៩ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ០១៤ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ០១៧ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧ និងសេចក្តីសម្រេចលេខ ០២០ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០១៧ ទុកជាបានការពេញទាំងមូល ។

មាត្រា ៣. សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៧ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៧

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ និងជាក្រុមប្រឹក្សាជំនុំជម្រះ

ប្រធាន

អ៊ឹម ឈុនលឹម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

- លេខ : ២៧១/០០៩/២០១៧
  ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០១៧
- លេខ : ២៧២/០១០/២០១៧
  ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០១៧
- លេខ : ២៧៣/០១១/២០១៧
  ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០១៧

សេចក្តីសម្រេច

លេខ : ១៦៣/០០៣/២០១៧ កបធ.ច
ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ ០១៥ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលតម្កល់សេចក្តីសម្រេចលេខ ០០២/១៧ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាប្រជុំសម្រេចឃុំត្រែងត្រយឹង ទុកជាបានការពេញទាំងមូល
- បានឃើញសេចក្តីសម្រេចលេខ ០១៦ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលតម្កល់សេចក្តីសម្រេចលេខ ០០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាប្រជុំសម្រេចសង្កាត់ចោមចៅ ទុកជាបានការពេញទាំងមូល

- បានឃើញសេចក្តីសម្រេចលេខ ០១៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលតម្កល់សេចក្តីសម្រេចលេខ ០០១/១៧ ០០៣/១៧ និង ០០៤/១៧ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាប្រជុំសម្រេចឃុំត្រែងត្រយឹង ទុកជាបានការពេញទាំងមូល
- បានឃើញលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ របស់លោក **អេង សំអាង** ជូនលោកស្រីមេធាវី **ម៉ែន សុភារី** ដើម្បីធ្វើជាមេធាវីតំណាងក្នុងការប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០១៥ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ និងសេចក្តីសម្រេចលេខ ០១៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ របស់លោក **សរ ណារ៉ាល់** ជូនលោកស្រីមេធាវី **ម៉ែន សុភារី** ដើម្បីធ្វើជាមេធាវីតំណាងក្នុងការប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០១៦ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ របស់លោកស្រីមេធាវី **ម៉ែន សុភារី** តំណាងឲ្យឈ្មោះ **អេង សំអាង** និងឈ្មោះ **សរ ណារ៉ាល់** ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០១៥ សេចក្តីសម្រេចលេខ ០១៦ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ និងសេចក្តីសម្រេចលេខ ០១៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោកស្រីមេធាវី **ម៉ែន សុភារី** កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ០៨០ គ.ជ.ប ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧទ្ទេសនាមឯកឧត្តម **ឌុច សុន** និងឯកឧត្តម **សោម សូរីដា** មកបំភ្លឺចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ លើពាក្យបណ្តឹងរបស់លោកស្រីមេធាវី **ម៉ែន សុភារី**
- បានឃើញកំណត់ហេតុបំភ្លឺរបស់ឯកឧត្តម **ឌុច សុន** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត ចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ភ្ជាប់ដោយសារណាចំនួន ០៣ ច្បាប់ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ និងឯកសារពាក់ព័ន្ធនឹងប្រជាពលរដ្ឋចំនួន ១៤ នាក់ ដែលត្រូវបានប្តឹងថាជាជនជាតិបរទេស (វៀតណាម)
- បានឃើញកំណត់ហេតុចុះស៊ើបអង្កេតរបស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៧ នៅឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ និងនៅសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
- បានឃើញលិខិតលេខ ១២១ គ.ជ.ប ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧទ្ទេសនាមឯកឧត្តម **សោម សូរីដា** និងលោក **ហួត ប៊ូរិន** ចូលរួមសវនាការជាសាធារណៈ ដើម្បីបំភ្លឺលើពាក្យបណ្តឹងរបស់លោកស្រីមេធាវី **ម៉ែន សុភារី**

- បានឃើញសេចក្តីសម្រេចលេខ ០០១/២០១៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពីការចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះ

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិការាយការណ៍

ក្រោយពីបានស្តាប់ការឆ្លើយបំភ្លឺរបស់លោកស្រីមេធាវី ម៉ៃ សុតារី

ក្រោយពីបានស្តាប់ការបំភ្លឺរបស់តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ របស់លោកស្រីមេធាវី **ម៉ៃ សុតារី** ទាំងបីស្ថិតក្នុងតំណាក់កាលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។ យោងតាមមាត្រា ៦២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងមាត្រា ២៦ ចំណុចទី៣ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បណ្តឹងនេះធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកមកពិនិត្យបាន
- យល់ឃើញថា នៅពេលឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជានៅពេលសវនាការជំនុំជម្រះជាសាធារណៈ លោកស្រីមេធាវី **ម៉ៃ សុតារី** បានបញ្ជាក់ដូចខាងក្រោម ៖
  - ចំពោះសំណុំរឿងលេខ ២៧១/០០៩/២០១៧ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ លោកស្រីបញ្ជាក់ថា៖ កាលសវនាការនៅ គ.ជ.ប ឈ្មោះ **ធុច សូនី** ថាគាត់ជាខ្មែរ ឱពុកគាត់ជាជនជាតិខ្មែរ ម្តាយគាត់ជាជនជាតិរៀតណាម ប៉ុន្តែគ្មានឯកសារបញ្ជាក់ថាគាត់ជាខ្មែរទេ។
  - ចំពោះសំណុំរឿងលេខ ២៧២/០១០/២០១៧ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ លោកស្រីបញ្ជាក់ថា៖ ឈ្មោះទាំង ១០ នាក់ បានចុះឈ្មោះបោះឆ្នោតដោយមានអត្តសញ្ញាណប័ណ្ណ ផ្អែកលើមាត្រា៥១ នៃច្បាប់បោះឆ្នោត តែបើផ្អែកលើមាត្រា ៤៦ នៃច្បាប់បោះឆ្នោតវិញ គឺផ្អែកលើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ គាត់ត្រូវសុំចូលសញ្ជាតិសិន ទើបធ្វើអត្តសញ្ញាណប័ណ្ណបាន បើខ្វះលក្ខខណ្ឌសញ្ជាតិមិនអាចបោះឆ្នោតបានទេ។ គាត់និយាយខ្មែរមិនច្បាស់នាំឲ្យបង្ហាញថាគាត់មិនមែនជាខ្មែរពិតប្រាកដទេ។ គ.ជ.ប អត់បានគិតពីលក្ខខណ្ឌសញ្ជាតិទេ គឺគិតត្រឹមតែឲ្យតែមានអត្តសញ្ញាណប័ណ្ណ គឺចុះឈ្មោះឲ្យ។
  - ចំពោះសំណុំរឿងលេខ ២៧៣/០១១/២០១៧ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ លោកស្រីបញ្ជាក់ថា៖ ពួកគាត់ជាចុងចម្លើយ សុទ្ធតែបានចុះឈ្មោះបោះឆ្នោតផ្អែកលើអត្តសញ្ញាណប័ណ្ណ បើគាត់មិនគោរពលក្ខខណ្ឌសញ្ជាតិទេ ដូច្នេះអត្តសញ្ញាណប័ណ្ណរបស់គាត់គ្មានលក្ខខណ្ឌគតិយុត្តយកមកបោះឆ្នោតបានទេ។ ឈ្មោះ **សុខ ជើង** និង **ព្រំ ចៅ** មានវិហារនៅទល់មុខផ្ទះគាត់ ពេលជួបជុំគ្នា ពួកគាត់និយាយតែភាសារៀតណាមទេ។
  - ចំពោះសំណុំរឿងទាំងបី លោកស្រីបានបញ្ជាក់បន្ថែមបញ្ហាផ្លូវច្បាប់មួយចំនួនថា៖ ឈ្មោះទាំង ១៤ នាក់ ដែលលោកស្រីបានប្តឹង សុទ្ធតែមានអត្តសញ្ញាណប័ណ្ណ ប៉ុន្តែមិនស្របតាម

មាត្រា ១៦ និងមាត្រា ២០ នៃច្បាប់ស្តីពីសញ្ជាតិ ដែលទាមទារឲ្យបុគ្គលដែលចូលសញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ត្រូវមានព្រះរាជក្រឹត្យ និងធ្វើការស្បថនៅចំពោះមុខតុលាការកំពូល។ បើកាន់កាប់អត្តសញ្ញាណប័ណ្ណមិនបានឆ្លងកាត់នីតិវិធីច្បាប់ នោះអត្តសញ្ញាណប័ណ្ណនោះមិនមានតម្លៃគតិយុត្ត មិនអាចយកទៅប្រើប្រាស់បានទេ។ តាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប បានចែងថា កស្តុតាងត្រូវផ្តល់តាមគ្រប់មធ្យោបាយ។ កស្តុតាងក៏អាចជាកស្តុតាងផ្ទាល់មាត់ផងដែរ។

- លោកស្រីសំណូមពរមកក្រុមប្រឹក្សាធម្មនុញ្ញ លុបឈ្មោះជនបរទេសទាំងនោះចេញពីបញ្ជីបោះឆ្នោត ឆ្នាំ២០១៦ ។

- យល់ឃើញថា នៅចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្តម **ឌុច សុន** តំណាងឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបំភ្លឺដូចខាងក្រោម ៖

- គ.ជ.ប បានធ្វើសំណើទៅក្រសួងមហាផ្ទៃ ដើម្បីផ្តល់នីតានុកូលភាពអំពីអត្តសញ្ញាណប័ណ្ណ។ ក្នុងនោះក្រសួងមហាផ្ទៃបានឆ្លើយថា មានអត្តសញ្ញាណប័ណ្ណប្រភេទទី១ ប្រភេទទី២ និងប្រភេទទី៣ ។ អត្តសញ្ញាណប័ណ្ណប្រភេទទី១ និងទី២ ឥតមានទិន្នន័យនៅក្រសួងមហាផ្ទៃទេ។ បើចង់ស្រាវជ្រាវទិន្នន័យ មានតែអត្តសញ្ញាណប័ណ្ណប្រភេទទី៣ ទេ អាចផ្ទៀងផ្ទាត់ជាមួយទិន្នន័យក្នុងកុំព្យូទ័ររបស់ក្រសួងមហាផ្ទៃ។ តាមមាត្រា ៥១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គ.ជ.ប សម្រេចយកអត្តសញ្ញាណប័ណ្ណគ្រប់ប្រភេទ ហើយរាជរដ្ឋាភិបាលបានចេញអនុក្រឹត្យពន្យាសុពលភាពអត្តសញ្ញាណប័ណ្ណ ដើម្បីអាចយកមកចុះឈ្មោះបាន។ គ្រប់ឯកសារសម្រាប់ការចុះឈ្មោះបោះឆ្នោត សុទ្ធតែមានឈ្មោះ កេទ អាយុ រូបថត ដើម្បីបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ គ.ជ.ប ទាំងអស់។ ក្នុងសំណុំរឿងទាំងបីនេះ ឈ្មោះ **ង្វៃ ង៉ោ** និងឈ្មោះ **ស៊ុន សារិន** មានអត្តសញ្ញាណប័ណ្ណប្រភេទទី១ អ្នកទាំង១២នាក់ទៀត គឺកាន់អត្តសញ្ញាណប័ណ្ណប្រភេទទី៣។ ក្នុងមាត្រា ៦១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អ្នកប្តឹងត្រូវមានកស្តុតាងផ្ទុយ។ លោកស្រីមេធាវីមិនមានកស្តុតាងផ្ទុយ ដើម្បីឲ្យ គ.ជ.ប លុបឈ្មោះជនទាំងនោះទេ។

- ការសម្រេចរបស់ គ.ជ.ប គឺផ្អែកលើមាត្រា ៤៦ និងមាត្រា ៥១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ការត្រួតពិនិត្យ និងការស្រាវជ្រាវរបស់គ.ជ.ប តាមរយៈឯកសាររបស់ក្រុមចុះឈ្មោះបោះឆ្នោតឃុំត្រែងត្រយឹង និងសង្កាត់ចោមចៅបញ្ជូនមក គ.ជ.ប ឃើញថា អ្នកទាំង១៤នាក់ បានប្រើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមកចុះឈ្មោះបោះឆ្នោត និងបានមកចុះឈ្មោះបោះឆ្នោតនៅចំពោះមុខក្រុមចុះឈ្មោះបោះឆ្នោត។ ការកំណត់សញ្ជាតិរបស់បុគ្គលម្នាក់ៗ គេអាចសម្គាល់បានតាមរយៈលិខិតយថាភូតផ្លូវការចេញដោយអាជ្ញាធរមានសមត្ថកិច្ច។ ការធ្វើការស៊ើបអង្កេតទៅលើជនបរទេស ជាសមត្ថកិច្ចរបស់តុលាការ និងអាជ្ញាធរមានសមត្ថកិច្ច។

- សំណូមពរ សូមឲ្យក្រុមប្រឹក្សាធម្មនុញ្ញ តម្កល់សេចក្តីសម្រេចលេខ ០១៥ និងសេចក្តីសម្រេចលេខ ០១៦ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ និងសេចក្តីសម្រេចលេខ ០១៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ ទុកជាបានការពេញទាំងមូល

- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ ឯកឧត្តម **សោម សូរីដា** តំណាងឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបំភ្លឺថា៖
  - គ.ជ.ប អនុវត្តភារកិច្ចរបស់ខ្លួនតាមគោលការណ៍ច្បាប់ តាមមាត្រា ៤៦ និងមាត្រា ៥១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលចែងអំពីលក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត។ លោកស្រីមេធាវីលើកឡើងមិនពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោតទេ ប៉ុន្តែបែរជាពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃការទទួលបានសញ្ជាតិខ្មែរទៅវិញ។ គ.ជ.បមិនមានសមត្ថកិច្ចក្នុងការស្រាវជ្រាវរកភាពត្រឹមត្រូវនៃការទទួលបានសញ្ជាតិខ្មែរទេ។ តាមមាត្រា ៦១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដើមបណ្តឹងត្រូវស្វែងរកភស្តុតាងដាក់បន្ទុកក្នុងការប្តឹងជំទាស់។ ចំណុចដែលថាភស្តុតាងត្រូវផ្តល់តាមគ្រប់មធ្យោបាយ មិនមានចែងនៅក្នុងបទបញ្ជានិងនីតិវិធីរបស់ គ.ជ.ប ទេ។ នៅក្នុងបទបញ្ជានិងនីតិវិធីរបស់ គ.ជ.ប ក៏មិនមានចែងថា ចុងចម្លើយត្រូវតែមានវត្តមាននៅក្នុងសវនាការដែរ។ ផ្អែកតាមបច្ចេកទេសក្នុងការស្រាវជ្រាវរបស់ គ.ជ.ប ជនទាំង ១៨ នាក់ដែលលោកស្រីមេធាវីបានប្តឹងសុទ្ធតែមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ហើយភាគច្រើនជាអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរប្រភេទទី៣។
  - សំណូមពរ សូមឲ្យក្រុមប្រឹក្សាធម្មនុញ្ញ តម្កល់សេចក្តីសម្រេចលេខ ០១៥ និងសេចក្តីសម្រេចលេខ ០១៦ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ និងសេចក្តីសម្រេចលេខ ០១៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ ទុកជាបានការ។

- យល់ឃើញថា លោកស្រីមេធាវី **ម៉ែន សុភារី** ដែលបានប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០១៥ លេខ ០១៦ និង លេខ ០១៩ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងការលុបឈ្មោះជនជាតិបរទេស (វៀតណាម) ពុំមានឯកសារ ឬ ភស្តុតាងជាលាយលក្ខណ៍អក្សរ ដែលអាចឲ្យក្រុមប្រឹក្សាធម្មនុញ្ញបដិសេធសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងបីនេះបានឡើយ

- យល់ឃើញថា តាមការចុះស៊ើបអង្កេតរបស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ប្រជាពលរដ្ឋដែលត្រូវលោកស្រីមេធាវី **ម៉ែន សុភារី** ប្តឹង សុទ្ធតែបានបំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោតគ្រប់គ្រាន់តាមច្បាប់ បទបញ្ជា និង នីតិវិធីចុះឈ្មោះបោះឆ្នោត

- យល់ឃើញថា សេចក្តីសម្រេចលេខ ០១៥ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ០១៦ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ និងសេចក្តីសម្រេចលេខ ០១៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានមូលដ្ឋានគតិយុត្តត្រឹមត្រូវ

- យល់ឃើញថា ការបញ្ជាក់អំពីធាតុពិតនៃអត្តសញ្ញាណរបស់បុគ្គលណាម្នាក់ មិនមែនជាសមត្ថកិច្ច របស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ។

សម្រេច

ចំពោះមុខដើមបណ្តឹង និង ចំពោះមុខគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

មាត្រា ១- ទទួលពាក្យបណ្តឹងចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ របស់លោកស្រីមេធាវី **ម៉ែន សុភាទី** តំណាងដោយអាណត្តិឲ្យលោក **អេង សំអាន** និង លោក **សរ ណារ៉ា** ភ្នាក់ងារគណបក្ស សង្គ្រោះជាតិ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

មាត្រា ២- តម្កល់សេចក្តីសម្រេចលេខ ០១៥ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ០១៦ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ និងសេចក្តីសម្រេចលេខ ០១៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

មាត្រា ៣- សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និងជាក្រុមប្រឹក្សាជំនុំជម្រះ

ប្រធាន

អ៊ឹម ឈុនលឹម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

.....

ក្រុមប្រឹក្សាធម្មនុញ្ញ
ចុល
លេខ 241/009/2017
ថ្ងៃ...23 មតា 2017...
ហ្ជាន..16:40 ឯ....

ពាក្យបណ្តឹង

នាងខ្ញុំមេធាវី **ម៉ែង សុតារី** ការិយាល័យផ្ទះលេខ៨៧C ផ្លូវលេខ៣៤៨ សង្កាត់ឃ្ជូញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរសព្ទ័លេខ០១២ ៥៦៥២ ៣៨ ជាមេធាវីតំណាងឱ្យឈ្មោះ **អេង សំអាង** កេទប្រុស ថ្ងៃខែឆ្នាំកំណើត២០-១០-១៩៦៣ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិទី២ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

សូមគោរពជូន
ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

កម្មវត្ថុ: ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ០១៥ ចុះថ្ងៃទី១៧/០១/ ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

យោង: - លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិចុះថ្ងៃទី២៣/០១/២០១៧ របស់ឈ្មោះ អេង សំអាង
- សេចក្តីសម្រេចលេខ០១៥ ចុះថ្ងៃទី១៧/០១/២០១៧ របស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម** មេត្តាជ្រាបថា លោក អេង សំអាង កើតទុក្ខមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចរក្សាទុកឈ្មោះ ធុច សូនី អោយនៅក្នុងបញ្ជីឈ្មោះបោះឆ្នោតដំបូងឆ្នាំ២០១៦ ដដែល ។ មូលហេតុដែលលោក អេង សំអាង ប្តឹងឱ្យលុបឈ្មោះជនបរទេសនេះ ដោយសារ ជននេះពុំមានសញ្ញាតិខ្មែរ ស្របតាមមាត្រា៤៦ នៃច្បាប់ស្តីពីការបោះឆ្នោតតំណាងរាស្ត្រ ម្យ៉ាងទៀតក្នុងសវនាការជាសាធារណៈនៅ គណកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុងចម្លើយបានទទួលស្គាល់ថាម្តាយខ្លួនជាជនជាតិរៀតណាមពិតមែន ហើយថាឪពុកខ្លួនជាជនជាតិខ្មែរ ប៉ុន្តែពុំមានឯកសារបញ្ជាក់ទេ ។ រីឯសេចក្តីសម្រេចរបស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោតក៏ពុំមានសំអាងហេតុឲ្យបានច្បាស់លាស់។

សំនូមពរ: -សុំចុះស៊ើបអង្កេតដល់ទីកន្លែងរស់នៅរបស់ចុងចម្លើយ
-សុំលុបឈ្មោះ ធុច សូនី កេទស្រី ចេញពីការយាល័យបោះឆ្នោតលេខ ១០៤៥ ក្នុងបញ្ជីបោះឆ្នោតដំបូង ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

សូម **ឯកឧត្តម** ទទួលនូវការគោរពដ៏ស្មោះអំពីខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១៧
ហត្ថលខា និងត្រា

ព្រះរាជាណាចក្រកម្ពុជា
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី.ម៉ែង.សុតារី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

ខ្ញុំឈ្មោះ .... ភេទ .... អាយុ ....54.......... ឆ្នាំ

មានទីលំនៅផ្ទះលេខ.................. ផ្លូវ.......................ភូមិ...ទី ២............. ឃុំ/សង្កាត់...................

ស្រុក/ក្រុង/ខណ្ឌ.. រាជធានី/ខេត្ត..

ទូរស័ព្ទលេខ.. ។

សូមប្រគល់សិទ្ធិជូន

លោក/លោកស្រី .... ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យផ្ទះលេខ ...87C......... ផ្លូវលេខ..348.......... សង្កាត់..................... ខណ្ឌ......................... រាជធានីភ្នំពេញ ដើម្បីធ្វើជាមេធាវីតំណាងរបស់ខ្ញុំក្នុងការប្ដឹងជំទាស់ទៅនឹងសេចក្ដីសម្រេចលេខ.....015................ ចុះថ្ងៃទី ..17-1-2017.............................. របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទៅក្រុមប្រឹក្សាធម្មនុញ្ញ និងការពារសំណុំរឿងនៅក្រុមប្រឹក្សាធម្មនុញ្ញតាមនីតិវិធី ។

លោក/លោកស្រីមេធាវីតំណាងដោយអាណត្តិ មានសិទ្ធិអនុវត្តនូវកិច្ចការខាងលើតាមច្បាប់ ដែលខ្ញុំបានប្រគល់ជូនខាងលើចាប់ពីថ្ងៃផ្ដិតស្នាមមេដៃ/ចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..23..ខែ..មករា.. ឆ្នាំ២០១៧

អ្នកប្រគល់សិទ្ធិ

....

បានឃើញ និង យល់ព្រម

ធ្វើជាអ្នកតំណាងដោយអាណត្តិ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..23.. ខែ..មករា.. ឆ្នាំ២០១៧

ហត្ថលេខា និង ត្រា

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី ម៉េង សុភារី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

.....

ក្រុមប្រឹក្សាធម្មនុញ្ញ
ចុល
លេខ.272/010/2017
ថ្ងៃ.....23.មនា.2017
បញ្ជាន.....16:40 ភ្លឹ..

ពាក្យបណ្តឹង

នាងខ្ញុំមេធាវី **ម៉ែង សុតារី** ការិយាល័យផ្ទះលេខ៨៧C ផ្លូវលេខ៣៤៨ សង្កាត់ឃ្ជូញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរសព្ទ័លេខ០១២ ៥៦៥២ ៣៨ ជាមេធាវីតំណាងឱ្យឈ្មោះ **សរ ណាល់** ភេទប្រុស ថ្ងៃខែឆ្នាំកំណើត២១-៤-១៩៦៩ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅផ្ទទះលេខ៤២ ផ្លូវលំ ភូមិព្រៃជីសាក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

សូមគោរពជូន
ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

កម្មវត្ថុ: ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០១៦ ចុះថ្ងៃទី១៧/០១/ ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

យោង: - លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិចុះថ្ងៃទី២២/០១/២០១៧ របស់ឈ្មោះ សរ ណាល់
- សេចក្តីសម្រេចលេខ០១៦ ចុះថ្ងៃទី១៧/០១/២០១៧ របស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម** មេត្តាជ្រាបថា លោកសរ ណាល់ កើតទុក្ខមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចរក្សាទុកឈ្មោះជនដូចមានក្នុងពាក្យបណ្តឹងចំនួន១០នាក់ អោយនៅក្នុងបញ្ជីឈ្មោះ (10នាក់) បោះឆ្នោតដំបូងឆ្នាំ២០១៦ដដែល ។ មូលហេតុដែលលោក សរ ណាល់ ប្តឹងឱ្យលុបឈ្មោះជនបរទេសនេះ ដោយសារ ជននេះពុំមានសញ្ញាតិខ្មែរ ស្របតាមមាត្រា៤៦ នៃច្បាប់ស្តីពីការបោះឆ្នោតតំណាងរាស្ត្រ ពីព្រោះ លោក សរ ណាល់ ជាអ្នករស់នៅក្នុងសង្កាត់ចោមចៅជាប់មករហូត ហើយលោក សរ ណាល់ស្គាល់យ៉ាងច្បាស់ ថាចុងចម្លើយ គឺពិតជាពលរដ្ឋវៀតណាម ដែលបានមករស់នៅសង្កាត់ចោមចៅនេះ ។ម្យ៉ាងទៀត សេចក្តីសម្រេចរបស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោតក៏ពុំមានសំអាងហេតុឲ្យបានច្បាស់លាស់ក្នុងការសម្រេចនេះទេ ។

សំនូមពរ: -សុំចុះស៊ើបអង្កេតដល់ទីកន្លែងរស់នៅរបស់ចុងចម្លើយ
-សុំលុបឈ្មោះជនបរទេសទាំង១០នាក់ដូចមានក្នុងពាក្យបណ្តឹង ចេញពីបញ្ជីបោះឆ្នោតដំបូងរបស់សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

សូម **ឯកឧត្តម** ទទួលនូវការគោរពដ៏ស្មោះអំពីខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១៧

ហត្ថលុខា និងត្រា

ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី.ម៉ែង.សុតារី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

ខ្ញុំឈ្មោះ **សរ ណាល់** ភេទប្រុស ឆ្នាំកំណើត១៩៦៩ មានទីលំនៅផ្ទះលេខ៤២ ផ្លូវលំ ភូមិព្រៃជីសាក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០៨១ ៨០ ៨០ ៥៨ ។

សូមប្រគល់សិទ្ធិដូន

លោក/លោកស្រី **ម៉ែន សុភារី** ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យផ្ទះលេខ ៨៧ ផ្លូវលេខ៣៥៨ សង្កាត់ឃ្មួញ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដើម្បីធ្វើជាមេធាវីតំណាងរបស់ខ្ញុំក្នុងការប្តឹងជំទាស់ ទៅនឹងសេចក្តីសម្រេចលេខ០១៦ ចុះថ្ងៃទី ១៧ មករា ២០១៧ របស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោតទៅក្រុមប្រឹក្សាធម្មនុញ្ញ និងការពារសំណុំរឿងនៅក្រុមប្រឹក្សាធម្មនុញ្ញតាមនីតិវិធី ។

លោក/លោកស្រីមេធាវីតំណាងដោយអាណត្តិ មានសិទ្ធិអនុវត្តនូវកិច្ចការខាងលើតាមច្បាប់ ដែលខ្ញុំបានប្រគល់ជូនខាងលើចាប់ពីថ្ងៃផ្តិតស្នាមមេដៃ/ចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧
អ្នកប្រគល់សិទ្ធិ

សរ ណាល់

បានឃើញ និង យល់ព្រម
ធ្វើជាអ្នកតំណាងដោយអាណត្តិ
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧
ហត្ថលេខា និង ត្រា

ATTORNEY AT LAW
KINGDOM OF CAMBODIA

មេធាវី ម៉ែន សុភារី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
ចុល
លេខ.273/011/2017
ថ្ងៃ....23.មតា..2017
បញ្ជាន..16:40 ម...

.....

ពាក្យបណ្តឹង

នាងខ្ញុំមេធាវី **ម៉ែង សុតារី** ការិយាល័យផ្ទះលេខ៨៧C ផ្លូវលេខ៣៤៨ សង្កាត់ឃ្លូញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរសព្ទ័លេខ០១២ ៥៦៥២ ៣៨ ជាមេធាវីតំណាងឱ្យឈ្មោះ **អេង សំអាង** ភេទប្រុស ថ្ងៃខែឆ្នាំកំណើត២០-១០-១៩៦៣ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិទី២ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

សូមគោរពជូន
ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

កម្មវត្ថុ: ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ០១៩ ចុះថ្ងៃទី១៨/០១/ ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

យោង: - លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិចុះថ្ងៃទី២៣/០១/២០១៧ របស់ឈ្មោះ អេង សំអាង
- សេចក្តីសម្រេចលេខ០១៩ ចុះថ្ងៃទី១៨/០១/២០១៧ របស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម** មេត្តាជ្រាបថា លោក អេង សំអាង កើតទុក្ខមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចរក្សាទុកឈ្មោះ ព្រំ ង៉ោ ឈ្មោះ សុខ ដើង ឈ្មោះ ផៃ ឡយ អោយនៅក្នុងបញ្ជីឈ្មោះបោះឆ្នោតដំបូងឆ្នាំ២០១៦ដដែល ។ មូលហេតុដែលលោក អេង សំអាង ប្តឹងឱ្យលុបឈ្មោះជនបរទេសនេះ ដោយសារ ជននេះពុំមានសញ្ញាតិខ្មែរ ស្របតាមមាត្រា៤៦ នៃច្បាប់ស្តីពីការបោះឆ្នោតតំណាងរាស្ត្រ ម្យ៉ាងទៀតក្នុងសវនាការជាសាធារណៈនៅគណកម្មាធិការជាតិរៀបចំការបោះឆ្នោត លោកស្រីមេឃុំត្រែងត្រយឹងបានបញ្ជាក់ថា ឈ្មោះ ព្រំ ង៉ោ ជាជនជាតិវៀតណាម ហើយឈ្មោះ ព្រំ ង៉ោ ក៏ទទួលស្គាល់ដូចគ្នា ថែមទាំងបានសុំឲ្យក្រុមប្រឹក្សាឃុំត្រែងត្រយឹងលុបឈ្មោះប្រពន្ធរបស់គាត់ឈ្មោះ សុខ ដើង ទៀតផង ប៉ុន្តែត្រូវបានលោកស្រីមេឃុំប្រាប់មិនឲ្យលុបទេ។ រីឯសេចក្តីសម្រេចរបស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោតក៏ពុំមានសំអាងហេតុឲ្យបានច្បាស់លាស់ក្នុងការសម្រេចរក្សាទុកឈ្មោះជនទាំងនេះក្នុងបញ្ជីបោះឆ្នោត ។

សំនូមពរ: -សុំចុះស៊ើបអង្កេតដល់ទីកន្លែងរស់នៅរបស់ចុងចម្លើយ
-សុំលុបឈ្មោះ ព្រំ ង៉ោ ឈ្មោះ សុខ ដើង ឈ្មោះ ផៃ ឡយ ចេញពីបញ្ជីបោះឆ្នោតដំបូង ក្នុងឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

សូម **ឯកឧត្តម** ទទួលនូវការគោរពដ៏ស្មោះអំពីនាងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១៧

ហត្ថលេខា និងត្រា

ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី.ម៉ែង_សុតារី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

ខ្ញុំឈ្មោះ .... ភេទ .... អាយុ .....64..... ឆ្នាំ
មានទីលំនៅផ្ទះលេខ .... ផ្លូវ .... ភូមិ .... ឃុំ/សង្កាត់ ....
ស្រុក/ក្រុង/ខណ្ឌ .... រាជធានី/ខេត្ត ....
ទូរស័ព្ទលេខ .... ។

<u>សូមប្រគល់សិទ្ធិជូន</u>

លោក/លោកស្រី .... ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យផ្ទះលេខ .....87 C..... ផ្លូវលេខ .....548..... សង្កាត់ .... ខណ្ឌ .... រាជធានីភ្នំពេញ ដើម្បីធ្វើជាមេធាវីតំណាងរបស់ខ្ញុំក្នុងការប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចលេខ .....19..... ចុះថ្ងៃទី .....18-1-2017..... របស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោតទៅក្រុមប្រឹក្សាធម្មនុញ្ញ និងការពារសំណុំរឿងនៅក្រុមប្រឹក្សាធម្មនុញ្ញតាមនីតិវិធី ។

លោក/លោកស្រីមេធាវីតំណាងដោយអាណត្តិ មានសិទ្ធិអនុវត្តនូវកិច្ចការខាងលើតាមច្បាប់ ដែលខ្ញុំបានប្រគល់ជូនខាងលើចាប់ពីថ្ងៃផ្តិតស្នាមមេដៃ/ចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី 23 ខែ ...... ឆ្នាំ២០១៧
<u>អ្នកប្រគល់សិទ្ធិ</u>

....

បានឃើញ និង យល់ព្រម
ធ្វើជាអ្នកតំណាងដោយអាណត្តិ
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី 23 ខែ ...... ឆ្នាំ២០១៧
ហត្ថលេខា និង ត្រា

មេធាវី
AVOCAT
ATTORNEY AT LAW
KINGDOM OF CAMBODIA

ចោម.ម៉េង_សុគារី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ...១៣..អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីអធិការកិច្ចផ្នែកកសិកម្ម និងជីកសិកម្ម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/ ៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៅក្នុងនាយកដ្ឋាន...

ផែនការនិងស្ថិតិនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១ .–

អនុក្រឹត្យនេះកំណត់នូវការបង្កើតឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម សម្រាប់បំពេញការងារអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងថ្នាំកសិកម្មនិងជីកសិកម្ម នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

មាត្រា២ .–

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិនេះ ត្រូវបានអនុញ្ញាតឱ្យមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម រួមមានមន្ត្រីដែលបម្រើការងារនៅនាយកដ្ឋាននីតិកម្មកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រើសម្រាប់៖

១- បំពេញបេសកកម្មពាក់ព័ន្ធនឹងការងារអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម។

២- ចូលរួមសវនាការនៅតុលាការ។

៣- ចូលរួមពិធីផ្លូវការផ្សេងៗ។

ជំពូកទី២

ឯកសណ្ឋាន

មាត្រា៣ .–

ឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម មានដូចខាងក្រោម៖

១- សម្លៀកបំពាក់(អាវ ខោ និងសំពត់)។

២- មួក។

៣- ខ្សែក្រវាត់ ស្បែកជើង និងស្រោមជើង។

មាត្រា៤ .-

សម្លៀកបំពាក់របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មត្រូវបានកំណត់យកប្រភេទសាច់ក្រណាត់ពណ៌កាគីខ្ចី ដូចខាងក្រោម៖

១- ថ្នាក់ដឹកនាំនាយកដ្ឋាន មន្ទីរ និងការិយាល័យ

១.១- ចំពោះបុរស

- អាវដៃខ្លី កបើក ប៉ូលស្មាសងខាង ឆែកខ្នង មានឡេវរូបព្រះ៣ជសង្ហារពណ៌មាសចំនួន ៥(ប្រាំ)គ្រាប់ និងមានហោប៉ៅបួន ហោប៉ៅពីរខាងលើដេរបត់កណ្តាលគម្របរាងស្លឹកពោធិ៍ ហោប៉ៅពីរខាងក្រោមគ្មានផ្នត់កណ្តាល គម្របរាងចតុកោណកែង និងមានឡេវរូបព្រះរាជសង្ហារពណ៌មាសចំនួន៤(បួន)គ្រាប់
- ខោជើងវែងដេរអំពីសាច់ក្រណាត់ និងពណ៌ដូចអាវ ចង្កេះដេរត ថ្នេរបង្កប់ជីបភ្លីខាងមុខពីរ មានហោប៉ៅបួន ហោប៉ៅខាងក្រោយពីរដេរបង្កប់ គម្របរាងស្លឹកពោធិ៍ និងហោប៉ៅពីរទៀតនៅចំហៀងដេរបង្កប់តាមថ្នេរ។

១.២- ចំពោះស្ត្រី

- អាវដូចបុរស តែម៉ូតអាវរាងស្ត្រី
- សំពត់ខ្លី មានសាច់ក្រណាត់ និងពណ៌ដូចអាវកាត់ស្រុងក្រោមជង្គង់ ឆែកក្រោយ រូតខាងក្រោយ ឬខោម៉ូតដូចបុរស តែគ្មានហោប៉ៅក្រោយ។

២- ថ្នាក់មន្ត្រី

២.១- ចំពោះបុរស

- អាវដៃវែង កឌុប ប៉ូលស្មាសងខាង ហោប៉ៅពីរដេរបត់ផ្នត់កណ្តាលគម្របរាងស្លឹកពោធិ៍ កាត់ស្រុងជើងត្រង់ដាក់ក្នុងខោ
- ខោជើងវែងដេរអំពីសាច់ក្រណាត់ និងពណ៌ដូចអាវ ចង្កេះដេរត ថ្នេរបង្កប់ជីបភ្លីខាងមុខពីរ មានហោប៉ៅបួន ហោប៉ៅខាងក្រោយពីរដេរបង្កប់ គម្របរាងស្លឹកពោធិ៍ និងហោប៉ៅពីរទៀតនៅចំហៀងដេរបង្កប់តាមថ្នេរ។

២.២- ចំពោះស្ត្រី

- អាវដូចបុរស តែម៉ូតអាវរាងស្ត្រី និងដាក់អាវក្នុងសំពត់ឬខោ
- សំពត់ខ្លី មានសាច់ក្រណាត់និងពណ៌ដូចអាវកាត់ស្រុងក្រោមជង្គង់ ឆែកក្រោយ រូតខាងក្រោយ ឬខោម៉ូតដូចបុរស តែគ្មានហោប៉ៅក្រោយ។

គំរូសម្លៀកបំពាក់របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

មាត្រា៥ .-

មួករបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ជាមួកកាស្កែតធ្វើពីសាច់ក្រណាត់និងពណ៌ដូចសម្លៀកបំពាក់ ផ្នែកខាងមុខខាងលើមានភ្ជាប់រូបព្រះរាជសង្ឆារពណ៌មាស ទំហំកម្ពស់៧៨មិល្លីម៉ែត្រ ទទឹង ៦៨មិល្លីម៉ែត។ នៅខាងក្រោមព្រះរាជសង្ឆារនេះ មានកណ្តាប់ល្ហែប៉ានពណ៌បៃតង និងមានប៉ាក់ក្បាច់ផ្កាភ្ញី ទេសពណ៌មាសចំកណ្តាលខាងមុខដល់ជើងមួកឬគ្មានតាមថ្នាក់នីមួយៗ។ នៅផ្នែកក្រោមកណ្តាប់ល្ហែប៉ានពណ៌បៃតងមានខ្សែធ្នាក់វេញពណ៌មាស ហើយនៅចុងសងខាងខ្សែធ្នាក់វេញនេះមានភ្ជាប់ឡេវរូបព្រះរាជសង្ឆារពណ៌មាសចំនួន២(ពីរ)គ្រាប់។ ក្បាំងមួកមានពណ៌ខ្មៅ ផ្នែកខាងមុខនៃក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសនៅចំកណ្តាល និងអមដោយក្បាច់សន្លឹកភ្ញីទេសពណ៌មាសទម្រង់ស្នែងក្របីដល់ជើងមួក ឬពាក់កណ្តាលជើងមួកឬគ្មានតាមថ្នាក់នីមួយៗ។ គែមរបស់ក្បាំងមួកមានវណ្ឌទំហំ៥មិល្លីម៉ែត្រពណ៌មាសព័ទ្ធដល់ជើងមួកឬគ្មានតាមថ្នាក់នីមួយៗ។

មួកកាស្កែតនេះត្រូវបានកំណត់ជា ៥(ប្រាំ)ថ្នាក់ដូចខាងក្រោមៈ

១- ថ្នាក់ប្រធានការិយាល័យកង្ឆាន

ផ្នែកខាងមុខខាងលើមានភ្ជាប់រូបព្រះរាជសង្ឆារពណ៌មាស នៅលើកណ្តាប់ល្ហែប៉ានពណ៌បៃតងមានប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសចំកណ្តាលខាងមុខដល់ជើងមួក។ នៅផ្នែកក្រោមប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសនេះមានខ្សែធ្នាក់វេញពណ៌មាស ហើយនៅចុងសងខាងខ្សែធ្នាក់វេញនេះមានភ្ជាប់ឡេវរូបព្រះរាជសង្ឆារពណ៌មាស។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ផ្កាភ្ញីទេសនៅចំកណ្តាលនិងអមដោយក្បាច់សន្លឹកភ្ញីទេសម្ខាងប្រាំមួយទងពណ៌មាសទម្រង់ស្នែងក្របីចុងសងខាងដល់ជើងមួក និងគែមរបស់ក្បាំងមួកមានវណ្ឌទំហំ៥មិល្លីម៉ែត្រពណ៌មាសព័ទ្ធដល់ជើងមួក។

២- ថ្នាក់អនុប្រធានការិយាល័យកង្ឆាននិងប្រធានមន្ទីរ

ផ្នែកខាងមុខខាងលើមានភ្ជាប់រូបព្រះរាជសង្ឆារពណ៌មាស នៅលើកណ្តាប់ល្ហែប៉ានពណ៌បៃតងមានប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសចំកណ្តាលខាងមុខដល់ជើងមួក។ នៅផ្នែកក្រោមប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសនេះមានខ្សែធ្នាក់វេញពណ៌មាស ហើយនៅចុងសងខាងខ្សែធ្នាក់វេញនេះមានភ្ជាប់ឡេវរូបព្រះរាជសង្ឆារពណ៌មាស។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ផ្កាភ្ញីទេសនៅចំកណ្តាល និងអមដោយក្បាច់សន្លឹកភ្ញីទេសម្ខាងប្រាំមួយទងពណ៌មាសទម្រង់ស្នែងក្របីចុងសងខាងដល់ជើងមួក។

៣- ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាលនិងអនុប្រធានមន្ទីរ

ផ្នែកខាងមុខខាងលើមានភ្ជាប់រូបព្រះរាជសង្ឆារពណ៌មាស នៅលើកណ្តាប់ល្ហែប៉ានពណ៌បៃតងមិនមានប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសទេ មានខ្សែធ្នាក់វេញពណ៌មាស ហើយនៅចុងសងខាងខ្សែធ្នាក់វេញនេះមានភ្ជាប់ឡេវរូបព្រះរាជសង្ឆារពណ៌មាស។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ផ្កាភ្ញីទេសនៅចំកណ្តាល និងអមដោយក្បាច់សន្លឹកភ្ញីទេសម្ខាងបួនទងពណ៌មាសទម្រង់ស្នែងក្របី។

៤- ថ្លាក់អនុប្រធានការិយាល័យថ្លាក់កណ្តាល ប្រធានការិយាល័យ និងអនុប្រធានការិយាល័យនៃមន្ទីរ

ផ្នែកខាងមុខខាងលើមានភ្ជាប់រូបព្រះរាជសង្ហារពណ៌មាស នៅលើកណ្តាប់រ៉ណ្ឌាប៉ានពណ៌បៃតងមិនមានប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសទេ មានខ្សែធ្វាក់រវញពណ៌មាស ហើយនៅចុងសងខាងខ្សែធ្វាក់រវញនេះមានភ្ជាប់ឡេវរូបព្រះរាជសង្ហារពណ៌មាស។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ផ្កាភ្ញីទេសនៅចំកណ្តាល និងអមដោយក្បាច់សន្លឹកភ្ញីទេសម្ខាងពីរទងពណ៌មាសទម្រង់ស្នែងក្របី។

៥- ថ្លាក់មន្ត្រី

ផ្នែកខាងមុខខាងលើមានភ្ជាប់រូបព្រះរាជសង្ហារពណ៌មាស នៅលើកណ្តាប់រ៉ណ្ឌាប៉ានពណ៌បៃតងមិនមានប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសទេ មានខ្សែធ្វាក់រវញពណ៌មាសហើយនៅចុងសងខាងខ្សែធ្វាក់រវញនេះមានភ្ជាប់ឡេវរូបព្រះរាជសង្ហារពណ៌មាស។ នៅលើជាយក្បាំងពណ៌ខ្មៅមានវណ្ឌទំហំ៥មិល្លីម៉ែត្រពណ៌មាសព័ទ្ធដល់ជើងមួក។

គំរូមួករបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

មាត្រា៦ .-

ខ្សែក្រវាត់ ស្បែកជើង និងស្រោមជើងរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានកំណត់ដូចខាងក្រោម៖

១- ចំពោះបុរស

- ស្បែកជើងយ្លុបកខ្លី ស្បែកពណ៌ខ្មៅ និងមានស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវាត់ស្បែកពណ៌ខ្មៅ ក្បាលខ្សែក្រវាត់ពណ៌មាសទំហំទទឹង៣៨មិល្លីម៉ែត្រ និងបណ្តោយ ៦៥មិល្លីម៉ែត្រដែលមាននិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មនៅចំកណ្តាលនៃក្បាលខ្សែក្រវាត់។

២- ចំពោះស្ត្រី

- ស្បែកជើងយ្លុបកខ្លីមានកែងកម្ពស់៣០មិល្លីម៉ែត្រ ឬកែងរាបស្មើ ស្បែកពណ៌ខ្មៅ និងមានស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវាត់ស្បែកពណ៌ខ្មៅ ក្បាលខ្សែក្រវាត់ពណ៌មាសទំហំទទឹង៣៣មិល្លីម៉ែត្រ និងបណ្តោយ ៦៥មិល្លីម៉ែត្រ ដែលមាននិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មនៅចំកណ្តាលនៃក្បាលខ្សែក្រវាត់។

គំរូខ្សែក្រវាត់ ស្បែកជើង និងស្រោមជើងរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃ អនុក្រឹត្យនេះ។

ឯកូអឧីព
សញ្ញាសម្គាល់

មាត្រា៧ .-

សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានកំណត់ដូចខាងក្រោម៖

១- សញ្ញាសម្គាល់សម្រាប់ពាក់លើចុងកអាវទាំងសងខាង

តួសញ្ញាសម្គាល់នេះធ្វើពីលោហធាតុដែលមានរាងមូលមានអង្កត់ផ្ចិត៣០មិល្លីម៉ែត្រ ដែលជានិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្ម។

២- សញ្ញាសម្គាល់សម្រាប់ដេរភ្ជាប់លើដើមដៃអាវខាងស្តាំ

សញ្ញាសម្គាល់នេះ ជានិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្ម ដែលតួសញ្ញាសម្គាល់នេះត្រូវបានធ្វើពីសាច់ក្រណាត់ដោយមានលក្ខណៈភិនភាគដូចតទៅ៖

- មានអង្កត់ផ្ចិត៧០មិល្លីម៉ែត្រ សម្រាប់ដេរភ្ជាប់នៅដើមដៃអាវខាងស្តាំ ក្រោមថ្នេរស្មា៥០មិល្លីម៉ែត្រ ដោយកំណត់យកភ្លីធ្វើជាចំណុចកណ្តាល
- ផ្ទៃខាងក្នុងមានកម្រងកួរស្រូវពោតនិងផ្ការកឃ្មាសអមសងខាងជារង្វង់ស្នែងក្របីពណ៌មាសហ៊ុមព័ទ្ធដោយបូរពណ៌ក្រហមលាយខ្មៀវ ជាបីថ្នាក់ជួបគ្នាខាងចុង ដោយមានប្រាសាទកំពូលបីនៅចំកណ្តាល
- នៅគល់កួរស្រូវនិងផ្ការពោតមានកម្រងបូរពណ៌ទង់ជាតិច្នៃជាក្បាច់ដោយមានសរសេរអក្សរកាត់ "**ឆឆក**" ពណ៌ស តំណាងឱ្យនាយកដ្ឋាននីតិកម្មកសិកម្ម
- នៅក្រោមអក្សរកាត់មានស្ពឺគ្រឿងចក្រពណ៌មាសតំណាងឱ្យការវិវឌ្ឍរីកចម្រើនរបស់វិស័យកសិឧស្សាហកម្ម
- នៅខាងលើអក្សរកាត់មានរាងអក្សរ A ពណ៌ពងមាន់ តំណាងឱ្យសំណង់សិល្បការ និងទ្វារទឹក
- ផ្ទៃក្នុងចំកណ្តាលមានរូបសញ្ញារោងចក្រពណ៌ពងមាន់កំពុងបញ្ចេញសកម្មភាពដែលតំណាងឱ្យភាពរីកចម្រើននៃវិស័យកសិកម្ម ផ្តល់វត្ថុធាតុដើមឱ្យរោងចក្រគ្រប់ពេល ដើម្បីផលិតចេញនូវផលិតផលបម្រើសង្គម
- ផ្ទៃក្នុងផ្នែកខាងក្រោម មានវាលស្រែពណ៌បៃតងខ្ចី មានប្រព័ន្ធស្រោចស្រពទឹក តំណាងឱ្យភាពរីកចម្រើននៃវិស័យកសិកម្មលើដំណាំគ្រប់ប្រភេទ
- ផ្ទៃក្នុងផ្នែកខាងក្រោមនៅលើវាលស្រែមានសៀវភៅផ្ទៃពណ៌សគែមសងខាងពណ៌ក្រហមដែលមានចារឹកអក្សរ "**ច្បាប់កសិកម្ម**" នៅសងខាង និងមានខ្សែបន្ទាត់ចំនួន១០ ពណ៌ខៀវកាត់ទទឹង ដែលតំណាងឱ្យបណ្តាលិខិតបទដ្ឋានគិតយុត្តដែលទាក់ទងនឹងវិស័យកសិកម្ម
- ផ្ទៃក្នុងផ្នែកខាងលើពណ៌ផ្ទៃមេយ មានប្រាំកាំ៖ កាំទី១ រូបត្រាក់ទ័រ កាំទី២ រូបគោ ជ្រូក មាន់ កាំទី៣ រូបកែវស្ទង់ កាំទី៤ រូបត្រី កាំទី៥ រូបដើមឈើ ដែលតំណាងឱ្យភាពរីកចម្រើនលើវិស័យគ្រឿងយន្តកសិកម្ម ចិញ្ចឹមសត្ច ការសិក្សាស្រាវជ្រាវបច្ចេកទេស វិទ្យាសាស្ត្រ និងបំរស្សានធម្មជាតិ។

៣- សញ្ញាសម្គាល់សម្រាប់ដេរភ្ជាប់លើដើមដៃអាវខាងឆ្វេង

សញ្ញាសម្គាល់នេះ ជាសញ្ញាសម្គាល់ដែលមាននិមិត្តសញ្ញាជាអក្សរថា "**អធិការកិច្ចថ្នាំកសិកម្ម និងដីកសិកម្ម**" ដែលប៉ាក់សម្រាប់ដេរភ្ជាប់នៅលើដើមដៃអាវខាងឆ្វេងមានប្រវែង៥០មិល្លីម៉ែត្រពីថ្នេរស្មាអាវ ក្រណាត់ប៉ាក់កម្ពស់២២មិល្លីម៉ែត្រ និងមានបណ្តោយប្រវែង១០៥មិល្លីម៉ែត្រ។

៤- សញ្ញាសម្គាល់ឈ្មោះមន្ត្រីសម្រាប់ពាក់លើគម្របហោប៉ៅអាវស្តាំ

តួសញ្ញាសម្គាល់នេះធ្វើពីលោហធាតុ មានផ្ទៃពណ៌បៃតង គួសបន្ទាត់ពណ៌មាសជុំវិញតួអក្សរពណ៌ស មានបណ្តាយ១០០មិល្លីម៉ែត្រនិងទទឹង២០មិល្លីម៉ែត្រ ដែលត្រូវដាក់នៅលើហោប៉ាអាវខាងស្តាំ។ តួសញ្ញាសម្គាល់ត្រូវបានចែកចេញជាពីរផ្នែក ផ្នែកខាងស្តាំមានបណ្តោយ២៥មិល្លីម៉ែត្រ នៅចំកណ្តាលមាននិមិត្តសញ្ញារបស់"**នាយកដ្ឋាននីតិកម្មកសិកម្ម**" មានអង្កត់ផ្ចិត១៥មិល្លីម៉ែត្រនៅក្រោមសញ្ញាសម្គាល់នេះ មានអក្សរកាត់ "**នគក** ឬ **មកសក**"ពណ៌ស។ ផ្នែកខាងឆ្វេងមានបណ្តោយ៧៥មិល្លីម៉ែត្រ មានអក្សរពីរជួរខណ្ឌដោយឆ្នូតពណ៌មាស ជួរទី១សរសេរឈ្មោះមន្ត្រីសាមីជាអក្សរខ្មែរ មានកម្ពស់អក្សរ៥មិល្លីម៉ែត្រ និងជួរទី២សរសេរពីតួនាទីមន្ត្រីសាមីជាអក្សរខ្មែរមានកម្ពស់អក្សរ៣មិល្លីម៉ែត្រ។

៥- សញ្ញាសម្គាល់សម្រាប់ព្យួរលើឡេវគម្របហោប៉ាអាវស្តាំ

តួសញ្ញាសម្គាល់នេះធ្វើពីលោហធាតុរាងសំប៉ែតមាននិមិត្តសញ្ញារបស់ "**នាយកដ្ឋាននីតិកម្មកសិកម្ម**" មានអង្កត់ផ្ចិត៤៥មិល្លីម៉ែត្រ ភ្ជាប់ដោយបន្ទះស្បែកសម្រាប់ព្យួរនៅហោប៉ៅអាវខាងស្តាំ។

គំរូសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងដីកសិកម្ម ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះ។

ជំពូកទី៤
សញ្ញាសក្តិ

មាត្រា៨ .-

សញ្ញាសក្តិសម្រាប់ពាក់លើស្មាអាវទាំងសងខាងរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងដីកសិកម្មធ្វើឡើងពីលោហធាតុ ដែលមានរាងទ្រវែងស្ពចប្រវែង១៣២មិល្លីម៉ែត្រ មានទំហំខាងគល់ប្រវែង៥៧មិល្លីម៉ែត្រ ខាងចុងប្រវែង៤៥មិល្លីម៉ែត្រ និងមានរាងកោងជាមុំទាល ដោយត្រូវបានបែងចែកជា៥(ប្រាំ)ថ្នាក់ មានដូចខាងក្រោម៖

១- ថ្នាក់ប្រធាននាយកដ្ឋាន

សញ្ញាសក្តិនេះមានផ្ទៃពណ៌បៃតងចាស់ មានស៊ុមធ្មេញក្របីពណ៌មាសព័ទ្ធជុំវិញកម្រាស់៦មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសគល់ស៊ុមផ្នែកខាងក្រោមមានទំហំ១២មិល្លីម៉ែត្រ។ ក្នុងស៊ុមផ្នែកខាងលើមានឡេវរូបព្រះរាជសង្ខារពណ៌មាសទំហំអង្កត់ផ្ចិតប្រវែង១៦មិល្លីម៉ែត្រ នៅពីក្រោមឡេវព្រះរាជសង្ខារប្រវែង២០មិល្លីម៉ែត្រមាននិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មទំហំអង្កត់ផ្ចិតប្រវែង២៥មិល្លីម៉ែត្រ នៅពីក្រោមនិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មប្រវែង២០មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសតន្ទុយហង្សពណ៌មាសកម្ពស់១៤មិល្លីម៉ែត្រមានបណ្តោយជាប់ស៊ុមនៅពីក្រោមចម្លាក់ក្បាច់អង្គរភ្ញីទេសតន្ទុយហង្សពណ៌មាសនេះ មានខ្សែសយពណ៌មាស២ជាន់ចំនួន២ទំហំ១មិល្លីម៉ែត្រ និងមានបណ្តាយជាប់ស៊ុមនៅចន្លោះខ្សែសយទាំងពីរមានចារឹកអក្សរ"**នីតិកម្មកសិកម្ម**" ពណ៌មាស។

២- ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានមន្ទីរ

សញ្ញាសក្តិនេះមានផ្ទៃពណ៌បៃតងចាស់ មានស៊ុមធ្មេញក្របីពណ៌មាសព័ទ្ធជុំវិញកម្រាស់៦មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសគល់ស៊ុមផ្នែកខាងក្រោមមានទំហំ១២មិល្លីម៉ែត្រ។ ក្នុងស៊ុមផ្នែកខាងលើមានឡេវរូបព្រះរាជសង្ហារពណ៌មាសទំហំអង្កត់ផ្ចិតប្រវែង១៦មិល្លីម៉ែត្រ នៅពីក្រោមឡេវព្រះរាជសង្ហារប្រវែង២០មិល្លីម៉ែត្រ មាននិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មទំហំអង្កត់ផ្ចិតប្រវែង២៥មិល្លីម៉ែត្រ នៅពីក្រោមនិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មប្រវែង២០មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាសកម្ពស់១៤មិល្លីម៉ែត្រ មានបណ្តោយជាប់ស៊ុមនៅពីក្រោមចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាសនេះមានខ្សែសយពណ៌មាស១ជាន់ចំនួន២ទំហំ១,៥មិល្លីម៉ែត្រ និងមានបណ្តោយជាប់ស៊ុមនៅចន្លោះខ្សែសយទាំងពីរមានចារឹកអក្សរ"**នីតិកម្មកសិកម្ម**" ពណ៌មាស។

៣- ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាលនិងអនុប្រធានមន្ទីរ

សញ្ញាសក្តិនេះមានផ្ទៃពណ៌បៃតងចាស់ មានស៊ុមធ្មេញត្រីពណ៌មាសព័ទ្ធជុំវិញកម្រាស់ ៥មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេស គល់ស៊ុមផ្នែកខាងក្រោមមានទំហំ១២មិល្លីម៉ែត្រ។ ក្នុងស៊ុមផ្នែកខាងលើមានឡេវរូបព្រះរាជសង្ហារពណ៌មាសទំហំអង្កត់ផ្ចិតប្រវែង១៦មិល្លីម៉ែត្រ នៅពីក្រោមឡេវព្រះរាជសង្ហារប្រវែង២០មិល្លីម៉ែត្រ មាននិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មទំហំអង្កត់ផ្ចិតប្រវែង២៥មិល្លីម៉ែត្រ នៅពីក្រោមនិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មប្រវែង២០មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាសកម្ពស់១៤មិល្លីម៉ែត្រ មានបណ្តោយជាប់ស៊ុមនៅពីក្រោមចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាសនេះមានខ្សែសយពណ៌ប្រាក់២ជាន់ចំនួន២ទំហំ១មិល្លីម៉ែត្រ និងមានបណ្តោយជាប់ស៊ុមនៅចន្លោះខ្សែសយទាំងពីរមានចារឹកអក្សរ" **នីតិកម្មកសិកម្ម**" ពណ៌មាស។

៤- ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាល ប្រធានការិយាល័យ និងអនុប្រធានការិយាល័យនៃមន្ទីរ

សញ្ញាសក្តិនេះមានផ្ទៃពណ៌បៃតងចាស់ មានស៊ុមធ្មេញត្រីពណ៌មាសព័ទ្ធជុំវិញកម្រាស់៥មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសគល់ស៊ុមផ្នែកខាងក្រោមមានទំហំ១២មិល្លីម៉ែត្រ។ ក្នុងស៊ុមផ្នែកខាងលើមានឡេវរូបព្រះរាជសង្ហារពណ៌មាសទំហំអង្កត់ផ្ចិតប្រវែង១៦មិល្លីម៉ែត្រ នៅពីក្រោមឡេវព្រះរាជសង្ហារប្រវែង២០មិល្លីម៉ែត្រ មាននិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មទំហំអង្កត់ផ្ចិតប្រវែង២៥មិល្លីម៉ែត្រ នៅពីក្រោមនិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មប្រវែង២០មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាសកម្ពស់១៤មិល្លីម៉ែត្រ មានបណ្តោយជាប់ស៊ុមនៅពីក្រោមចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាសនេះមានខ្សែសយពណ៌ប្រាក់១ជាន់ចំនួន២ទំហំ១,៥មិល្លីម៉ែត្រ និងមានបណ្តោយជាប់ស៊ុមនៅចន្លោះខ្សែសយទាំងពីរមានចារឹកអក្សរ "**នីតិកម្មកសិកម្ម**" ពណ៌មាស។

៥- ថ្នាក់មន្ត្រី

សញ្ញាសក្តិនេះមានផ្ទៃពណ៌បៃតងចាស់ មានស៊ុមធ្មេញត្រីពណ៌មាសព័ទ្ធជុំវិញកម្រាស់ ៥មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសគល់ស៊ុមផ្នែកខាងក្រោមមានទំហំ១២មិល្លីម៉ែត្រ។ ក្នុងស៊ុមផ្នែកខាងលើមានឡេវរូបព្រះរាជសង្ហារពណ៌មាសទំហំអង្កត់ផ្ចិតប្រវែង១៦មិល្លីម៉ែត្រ នៅពីក្រោមឡេវព្រះរាជសង្ហារប្រវែង២០មិល្លីម៉ែត្រ មាននិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មទំហំអង្កត់ផ្ចិតប្រវែង២៥មិល្លីម៉ែត្រ នៅពីក្រោមនិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មប្រវែង២០មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយ

មាសកម្ពស់១៤មិល្លីម៉ែត្រ មានបណ្តោយជាប់ស៊ុម នៅពីក្រោមចម្លាក់ក្បាច់អង្គរភ្ជីទេសកន្ទុយហង្សពណ៌មាសនេះមានចារឹកអក្សរ "**នីតិកម្មកសិកម្ម**" ពណ៌មាស។

គំរូសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី៥ នៃអនុក្រឹត្យនេះ។

ជំពូកទី៥
ការផ្តល់និងប្រើឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ

មាត្រា៩ .-

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ ដូចបានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវបានផ្តល់ជូនមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម នៃនាយកដ្ឋាននីតិកម្មកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងម្នាក់ចំនួន២(ពីរ)សម្រាប់ ដើម្បីប្រើក្នុងរយៈពេល១(មួយ)ឆ្នាំ។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវប្រើថវិកាជាតិ និងមានលក្ខណៈសមស្របទៅនឹងទំហំនៃថវិកាជាតិប្រចាំឆ្នាំដែលបានផ្តល់វិភាជន៍ជូន។

មាត្រា១០ .-

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានប្រើដូចមាននៅក្នុងឧបសម្ព័ន្ធទី៦នៃអនុក្រឹត្យនេះ។

ជំពូកទី៦
ទោសប្បញ្ញត្តិ

មាត្រា១១ .-

ជនណាដែលបានក្លែងឯកសណ្ឋាន សញ្ញាសម្គាល់ សញ្ញាសក្តិ ឬក្លែងបន្លំខ្លួនដោយស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន។

ជំពូកទី៧
អន្តរប្បញ្ញត្តិ

មាត្រា១២ .-

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ដែលកំពុងប្រើសព្វថ្ងៃត្រូវបន្តរហូតដល់មានឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិថ្មីមកជំនួស។

ជំពូកទី៨
អវសានប្បញ្ញត្តិ

មាត្រា១៣ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា១៤ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វេង សាខុន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃអនុក្រឹត្យ លេខ...០៣...អនក្រ.បក ចុះថ្ងៃទី...០២...ខែ...កម្ភៈ...ឆ្នាំ២០១៧
ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចផ្នាំកសិកម្មនិងជីកសិកម្ម

គំរូឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចផ្នាំកសិកម្មនិងជីកសិកម្ម

១. គំរូសម្លៀកបំពាក់

១.១. អាវផ្នាក់ដឹកនាំនាយកដ្ឋាន មន្ទីរ និងការិយាល័យ

ក.ចំពោះបុរស

ខាងមុខ

ខាងក្រោយ

ខ.ចំពោះស្ត្រី

ខាងមុខ

ខាងក្រោយ

១.២. ខ្លាក់មន្ត្រី

ខាងមុខ

ខាងក្រោយ

១.៣. ខោប្រុសនិងសំពត់ស្ត្រី

ឧបសម្ព័ន្ធទី២នៃអនុក្រឹត្យ លេខ...១.ក...អនក្រ.បក ចុះថ្ងៃទី.០៧...ខែ...ឧសភ...ឆ្នាំ២០១៧
"ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្ម"

២. គំរូមួក

	ថ្នាក់ប្រធាននាយកដ្ឋាន
	ថ្នាក់អនុប្រធាននាយកដ្ឋាន និងប្រធានមន្ទីរ
	ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាលនិង ថ្នាក់អនុប្រធានមន្ទីរ
	- ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាល - ប្រធានការិយាល័យ និងអនុប្រធានការិយាល័យ នៃមន្ទីរ
	ថ្នាក់មន្ត្រី

ឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យ លេខ ...១៣... អនក្រ.បក ចុះថ្ងៃទី ...០២... ខែ ...ឆ្នូ... ឆ្នាំ២០១៧
"ស្តីពី៦កសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអចិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្ម"

៣. គំរូខ្សែក្រទាត់ត់ ស្បែកជើង និងស្រោមជើង

	ខ្សែក្រទាត់ត់ចំពោះបុរស
	ខ្សែក្រទាត់ចំពោះស្ត្រី
	ស្បែកជើងចំពោះបុរស
	ស្បែកជើងចំពោះស្ត្រី
	ស្រោមជើង

ឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យ លេខ...១៣.....អនក្រ.បក ចុះថ្ងៃទី...០៧...ខែ...ឧសភ...ឆ្នាំ២០១៧
"ស្តីពី៦កសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអចិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម"

គំរូសញ្ញាសម្គាល់

	សញ្ញាសម្គាល់សម្រាប់ពាក់ លើចុងកអាវទាំងសងខាង
	សញ្ញាសម្គាល់សម្រាប់ដេរភ្ជាប់ លើដើមដៃអាវខាងស្តាំ
	សញ្ញាសម្គាល់សម្រាប់ ដេរភ្ជាប់លើដើមដៃអាវខាងឆ្វេង
	សញ្ញាសម្គាល់ឈ្មោះមន្ត្រី សម្រាប់ពាក់លើគម្របហោប៉ៅអាវស្តាំ
	សញ្ញាសម្គាល់សម្រាប់ព្យួរលើឡេវ គម្របហោប៉ៅអាវស្តាំ

ឧបសម្ព័ន្ធទី៥នៃអនុក្រឹត្យ លេខ...១៣.....អនក្រ.បក ចុះថ្ងៃទី០២...ខែ.កុម្ភៈ....ឆ្នាំ២០១៧
"ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចផ្នែកសិកម្មនិងជីវកសិកម្ម"

គំរូសញ្ញាសក្តិ

១. សញ្ញាសក្តិថ្នាក់ប្រធាននាយកដ្ឋាន

២. សញ្ញាសម្គាល់ឋានុប្រធាននាយកដ្ឋាននិងប្រធានមន្ទីរ

៣. សញ្ញាសក្តិថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាលនិងអនុប្រធានមន្ទីរ



៤. សញ្ញាសក្តិថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាល ប្រធានការិយាល័យ និងអនុប្រធានការិយាល័យ



៥. សញ្ញាសក្តិថ្នាក់មន្ត្រី



ឧបសម្ព័ន្ធទី៦នៃអនុក្រឹត្យ លេខ..៣៣.....អនក្រ.បក ចុះថ្ងៃទី..២៤..ខែ..កុម្ភៈ...ឆ្នាំ២០១៧
"ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចផ្នាំកសិកម្មនិងជីកសិកម្ម"

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ
របស់មន្ត្រីអធិការកិច្ចផ្នាំកសិកម្មនិងជីកសិកម្ម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...[illegible]...

អនុក្រឹត្យ

ស្តីពី

ការជំឡើងឋានន្តរស័ក្តិ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ : ជំឡើងឋានន្តរស័ក្តិថ្នាក់ វ៉រសេនីយ៍ឯក នាយទាហាននៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម៖

១-វ៉រសេនីយ៍ទោ	**គង់**	**ផល**	អត្តលេខ ០១២៨២៨	ជំនួយការ ឧត្តមសេនីយ៍ឯក ជា សារ៉ន
២-វ៉រសេនីយ៍ទោ	**សាក់**	**ប៉ានី**	អត្តលេខ ០១១៨៣៤	ជំនួយការ ឯកឧត្តម ម៉ាត់ ជាឡា
៣-វ៉រសេនីយ៍ទោ	**ឡេង**	**លីម៉ា**	អត្តលេខ ០៤៤៧២៨	នាយ ផ្នែកអត្តសញ្ញាណប័ណ្ណ ការិយាល័យទី១ កងទ័ពជើងគោក
៤-វ៉រសេនីយ៍ទោ	**ម៉ាន់**	**ណាប៉ា**	អត្តលេខ ០១៨៥០២	នាយរង ការិយាល័យការពារព្រំដែន កងទ័ពជើងគោក
៥-វ៉រសេនីយ៍ទោ	**ឡុង**	**សំណាង**	អត្តលេខ ០០៩០២២	នាយរង ការិយាល័យសុខាភិបាល កងទ័ពជើងគោក

៦-វរសេនីយ៍ទោ	ស៊ឹម	ណាតុច	អត្តលេខ ០០២៦៩០	នាយសេនាធិការរង បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក
៧-វរសេនីយ៍ទោ	ថាន់	ថារ៉ា	អត្តលេខ ០០៩២៧៤	នាយ លេខាធិការដ្ឋាន បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក
៨-វរសេនីយ៍ទោ	តុល	ថល	អត្តលេខ ០១៧៦០៧	នាយ ផ្នែកហឹរហឹន បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក
៩-វរសេនីយ៍ទោ	ពូន	ចំណាប់	អត្តលេខ ០៤៣៤៥០	នាយ ផ្នែកសំណង់យុទ្ធសាស្ត្រ បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក
១០-វរសេនីយ៍ទោ	ខេង	ប៊ុនឆឿន	អត្តលេខ ០៣៩៧៨០	នាយសេនាធិការរង បញ្ជាការដ្ឋានកាំភ្លើងធំ កងទ័ពជើងគោក
១១-វរសេនីយ៍ទោ	ស	សុទ្ធ	អត្តលេខ ០០៩៣៤០	នាយសេនាធិការរង កងពលតូច អន្តរាគមន៍លេខ១១ កងទ័ពជើងគោក
១២-វរសេនីយ៍ទោ	ង៉ាន់	ណូ	អត្តលេខ ០២៨៥៦៦	មេបញ្ជាការរង និងជា នាយសេនាធិការ តំបន់ប្រតិបត្តិការសឹករងត្បូងឃ្មុំ
១៣-វរសេនីយ៍ទោ	គង់	សាខុន	អត្តលេខ ០៤១២១២	មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងត្បូងឃ្មុំ
១៤-វរសេនីយ៍ទោ	យឿង	សារិន	អត្តលេខ ០២៦៧៣៣	ជំនួយការ ឯកឧត្តម យឿង សុខុន
១៥-វរសេនីយ៍ទោ	ស្វាយ	គង់	អត្តលេខ ១៥៧៨៥៣	មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងព្រះសីហនុ
១៦-វរសេនីយ៍ទោ	ប៉ាល់	សុផល	អត្តលេខ ០១៩០២១	នាយសេនាធិការរង យោធភូមិភាគទី ៤
១៧-វរសេនីយ៍ទោ	ផង់	ម៉ុលរិទ្ធ	អត្តលេខ ២១៧៦៦៩	មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងឧត្តរមានជ័យ
១៨-វរសេនីយ៍ទោ	ឃួន	តិរុណា	អត្តលេខ ០៤១៥៨៧	មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងឧត្តរមានជ័យ
១៩-វរសេនីយ៍ទោ	ឆួច	សារឿន	អត្តលេខ ០០៣១៥៩	នាយសេនាធិការរង យោធភូមិភាគពិសេស
២០-វរសេនីយ៍ទោ	នៃ	ឆិយម	អត្តលេខ ០២៧៨១៥	មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងកណ្តាល
២១-វរសេនីយ៍ទោ	អ៊ូប	ឃុច្បា	អត្តលេខ ០២២២៦៧	នាយមណ្ឌលយោធភូមិភាគទី១ ការិយាល័យទី២ កងទ័ពជើងគោក
២២-វរសេនីយ៍ទោ	សេង	ឥច្ឆ	អត្តលេខ ០៤១៤៤៥	មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងកោះកុង

២៣-វរសេនីយ៍ទោ	ឆួន	សុច្ឆ	អត្តលេខ ០១៥៦៥៨	មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងកោះកុង
២៤-វរសេនីយ៍ទោ	ចាន់	សុខន	អត្តលេខ ០០៤១៩០	មេបញ្ជាការរង និងជានាយសេនាធិការ កងពលតូចថ្មើរជើងលេខ២១
២៥-វរសេនីយ៍ទោ	ឌឹម	ប៊ុនឆឿន	អត្តលេខ ០៧៩០៦៦	នាយផ្នែកប្រេងឥន្ធនៈ ការិយាល័យទី៤ កងទ័ពជើងគោក
២៦-វរសេនីយ៍ទោ	ម៉ិន	ប៊ុនសេង	អត្តលេខ ០១៥៧៦៤	នាយលេខាធិការដ្ឋាន យោធភូមិភាគទី៥
២៧-វរសេនីយ៍ទោ	ភណ្ណា	សុភ័ណ្ឌា	អត្តលេខ ០០៤៩៩១	នាយការិយាល័យអភិវឌ្ឍន៍ យោធភូមិភាគទី៥
២៨-វរសេនីយ៍ទោ	ឆាយ	គីមហួរ	អត្តលេខ ០១៩៥២៥	នាយផ្នែកវិស្វកម្ម យោធភូមិភាគទី៥
២៩-វរសេនីយ៍ទោ	អេង	សុជា	អត្តលេខ ០២០៥៦២	មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងពោធិសាត់
៣០-វរសេនីយ៍ទោ	ច្រឹក	ណារ៉ែត	អត្តលេខ ០៣៥២៣៣	មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៣១-វរសេនីយ៍ទោ	កែវ	សុន	អត្តលេខ ០០៣៥០៩	មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងប៉ៃលិន
៣២-វរសេនីយ៍ទោ	យ៉ែម	ឡុម	អត្តលេខ ០១០៨១១	មេបញ្ជាការរង កងពលតូចថ្មើរជើងលេខ៥២
៣៣-វរសេនីយ៍ទោ	ម៉ែន	ចាន់តារា	អត្តលេខ ០១៨៤៦៣	មេបញ្ជាការរង វរសេនាធំលេខ៤២ យោធភូមិភាគទី១
៣៤-វរសេនីយ៍ទោ	ហួត	ចំរើនរិទ្ធ	អត្តលេខ ០១២៩០៤	មេបញ្ជាការរង វរសេនាធំលេខ៤២ យោធភូមិភាគទី១
៣៥-វរសេនីយ៍ទោ	សួន	ពិសិដ្ឋ	អត្តលេខ ០០២៦០២	នាយការិយាល័យទី៣ យោធភូមិភាគទី៥
៣៦-វរសេនីយ៍ទោ	គីម	រដ្ឋមុន្នី	អត្តលេខ ០៤៣៤៦៤	នាយការិយាល័យហ្វឹកហ្វឺន យោធភូមិភាគទី៥
៣៧-វរសេនីយ៍ទោ	រឿន	អេង	អត្តលេខ ០១០៦១០	នាយការិយាល័យយោធាតំបន់ យោធភូមិភាគទី៥
៣៨-វរសេនីយ៍ទោ	ជួង	តារា	អត្តលេខ ០១០៦៧៩	នាយករង សាលាពលទាហានទី៥ យោធភូមិភាគទី៥
៣៩-វរសេនីយ៍ទោ	ម៉ម	ស៊ីណាន	អត្តលេខ ០១៥៨១៤	មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងប៉ៃលិន

៤០-វរសេនីយ៍ទោ	**សួន**	**ច្រាជ្ញា**	អត្តលេខ ០៤២២៧៩	នាយរង អធិការកិច្ច បញ្ជាការដ្ឋានកងទ័ពជើងគោក
៤១-វរសេនីយ៍ទោ	**ចាន់**	**ឃុច**	អត្តលេខ ១៤៤៧០០	មេបញ្ជាការរង បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តសៀមរាប

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ឧទ្ធកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឧទ្ធកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ...៧៥...អនក្រ.៥៥

អនុក្រឹត្យ
ស្តីពី
ការបញ្ចប់ភារកិច្ចមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមុខងារសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា ១ .. បញ្ចប់ភារកិច្ច លោក **ស៊ុន ឌ៉ាន់ថន** ពីទីប្រឹក្សាក្រសួងមុខងារសាធារណៈ មានឋានៈស្មើប្រធាននាយកដ្ឋានដោយមូលហេតុសាមីខ្លួនសុំលាឈប់ពីការងារ។

មាត្រា ២ .. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែល ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មត្យា ឆ្នាំ ២០១៧

នាយកដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៧០.អនក្រ.៥៥

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមុខងារ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១: តែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូន ឧត្តមសេនីយ៍ទោ **គឹម រស្មី** អត្តលេខ០៣៦៧១៨ ជា អគ្គលេខាធិការរង ក្រសួងការពារជាតិ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ធកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ធកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៨១...អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- វរសេនីយ៍ទោ	**ឃឹម ភុទ្ធី**	អត្តលេខ	៦៦៧៧៨
២- វរសេនីយ៍ទោ	**តាត ចារិត**	អត្តលេខ	៧៧៩៩៩
៣- វរសេនីយ៍ទោ	**សួ ប៊ុនស៊ូ**	អត្តលេខ	៥៣៨០២

៤- វរសេនីយ៍ទោ **ឃឹម ចំណាន** អគ្គលេខ ១២៩៩៥ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ....អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការដំឡើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិក: ដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ដំឡើងឋានន្តរស័ក្តិ **ឧត្តសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០២រូប ដូចខាងក្រោម៖

១-លោកវរសេនីយ៍ទោ **ហួន ចាន់រតនៈ** អត្តលេខ ៦០៦៦៦

២-លោកវរសេនីយ៍ទោ **ឈិន កំសត់** អត្តលេខ ៦៣៣១៨ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តម្លើងឋានន្តរស័ក្តិថ្នាក់ **ចរសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១-	វរសេនីយ៍ទោ	**គឹម ស៊ឹម**	អត្តលេខ ០៥៧៥០
២-	វរសេនីយ៍ទោ	**ញ៉ែត ស៊ីណាត**	អត្តលេខ ០៥៥២០
៣-	វរសេនីយ៍ទោ	**សៀម សុតា**	អត្តលេខ ៦១៦៦៦ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ក្រម្ភៃ ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ធកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ធកាល័យឧបនាយករដ្ឋមន្ត្រី
- ជូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០៣៣០.....សហវ..ក.ប.ហ

ប្រកាស
ស្តីពី
ការគ្រប់គ្រងអាជីវកម្មធធួលបញ្ជាំ និងធធួលឡ្រាតិតោកដោយអនុប្បធាន

ធេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/១២០៨/០២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- បានឃើញព្រះរាជក្រមលេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋ-ប្បវេណីឆ្នាំ២០០៨
- បានឃើញអនុក្រឹត្យលេខ៤៨៨អនក្រ/បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ១៣៣០ សហវ.ប្រក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានក្រោមចំណុះអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh. Phnom Penh. CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

សម្រួច
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

ប្រការ១.-

ប្រកាសនេះមានគោលបំណងដូចខាងក្រោម÷

- ធានាប្រសិទ្ធភាពនៃការគ្រប់គ្រង និងការត្រួតពិនិត្យអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន
- ធានាសមធម៌ និងតុល្យភាពនៃផលប្រយោជន៍រវាងអ្នកដាក់បញ្ចាំ និងអ្នកទទួលទ្រព្យបញ្ចាំ
- បង្កើតឱ្យមានប្រព័ន្ធផ្គត់ផ្គង់សាច់ប្រាក់ឆាប់រហ័សដោយស្របច្បាប់ក្រៅពីប្រព័ន្ធធនាគារ
- រួមចំណែកទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានក្នុងវិស័យទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានដើម្បីធានានូវសន្តិសុខនិងសណ្តាប់ធ្នាប់សង្គម។

ប្រការ២.-

ប្រកាសនេះមានគោលដៅកំណត់ យន្តការ វិធាន និងនីតិវិធីនៃការគ្រប់គ្រង និងការត្រួតពិនិត្យប្រតិបត្តិការអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ៣.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសកម្មភាពពាក់ព័ន្ធនឹងអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ៤.-

ពាក្យបច្ចេកស័ព្ទដែលបានប្រើនៅក្នុងប្រកាសនេះត្រូវបានកំណត់ដូចខាងក្រោម÷

- **ក្រសួង** សំដៅដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **អគ្គនាយកដ្ឋាន** សំដៅដល់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **នាយកដ្ឋាន** សំដៅដល់នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុបញ្ចាំ និងប្រាតិភោគដោយអនុប្បទាននៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **មន្ទីរ** សំដៅដល់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត
- **អាជ្ញាបណ្ណ** សំដៅដល់លិខិតតតិយុត្តិដែលចេញដោយក្រសួង ដើម្បីអនុញ្ញាតឱ្យក្រុមហ៊ុន/សហគ្រាសណាមួយប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាននៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយស្របតាមលក្ខខណ្ឌដូចមានចែងក្នុងប្រកាសនេះ
- **លិខិតអនុញ្ញាតប្រកបអាជីវកម្ម** សំដៅដល់លិខិតដែលចេញដោយមន្ទីរ ដើម្បីអនុញ្ញាតឱ្យ ក្រុមហ៊ុន/សហគ្រាសណាមួយប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានខ្នាតតូចនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយស្របតាមលក្ខខណ្ឌដូចមានចែងក្នុងប្រកាសនេះ
- **អាជីវកម្មទទួលបញ្ចាំ** សំដៅដល់សកម្មភាពពាណិជ្ជកម្មដែលអតិថិជនយកទ្រព្យទៅដាក់បញ្ចាំ ដើម្បីទទួលបានប្រាក់កម្ចីដោយសន្យាទូទាត់សងប្រាក់ដើម និងការប្រាក់ទៅតាមកិច្ចសន្យាដែលបានកំណត់
- **អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន** សំដៅដល់សកម្មភាពពាណិជ្ជកម្មដែលអតិថិជនធ្វើអនុប្បទានសិទ្ធិលើចលនវត្ថុ របស់ខ្លួនជូនដល់អ្នកទទួលប្រាតិភោគដោយអនុប្បទាន ដើម្បីទទួលបានប្រាក់កម្ចីដោយសន្យាទូទាត់សងប្រាក់ដើម និងការប្រាក់ទៅតាមកិច្ចសន្យាដែលបានកំណត់
- **អ្នកទទួលបញ្ចាំ** សំដៅដល់នីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មទទួលទ្រព្យបញ្ចាំពីក្រសួង/មន្ទីរ

- **អ្នកទទួលប្រាតិភោគដោយអនុប្បទាន** សំដៅដល់នីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មទទួលទ្រព្យប្រាតិភោគដោយអនុប្បទានពីក្រសួង/មន្ទីរ
- **អ្នកដាក់បញ្ចាំ** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលយកទ្រព្យទៅដាក់បញ្ចាំជាមួយអ្នកទទួលបញ្ចាំ ដើម្បីទទួលបានប្រាក់កម្ចី
- **អ្នកដាក់ប្រាតិភោគដោយអនុប្បទាន** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលយកទ្រព្យទៅដាក់ប្រាតិភោគដោយអនុប្បទានជាមួយអ្នកទទួលប្រាតិភោគដោយអនុប្បទាន ដើម្បីទទួលបានប្រាក់កម្ចី
- **ទ្រព្យ** សំដៅដល់ចលនវត្ថុ ឬអចលនវត្ថុដែលជាកម្មវត្ថុយកទៅដាក់បញ្ចាំ
- **លោះ** សំដៅដល់ការទទួលយកមកវិញនូវទ្រព្យដែលបានដាក់បញ្ចាំ ឬដែលបានដាក់ប្រាតិភោគដោយអនុប្បទានក្រោយពីបានសងប្រាក់ដើម (ប្រាក់កម្ចី) និងការប្រាក់គ្រប់ចំនួនទៅតាមកិច្ចសន្យាដែលបានកំណត់ជូនទៅអ្នកទទួលបញ្ចាំ ឬអ្នកទទួលប្រាតិភោគដោយអនុប្បទានវិញ
- **កិច្ចសន្យា** សំដៅដល់កិច្ចសន្យាទទួលបញ្ចាំ ឬទទួលប្រាតិភោគដោយអនុប្បទានដែលធ្វើឡើងរវាងអ្នកដាក់បញ្ចាំ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទាន និងអ្នកទទួលបញ្ចាំ ឬអ្នកទទួលប្រាតិភោគដោយអនុប្បទាន។

ជំពូកទី២
ស្ថាប័នគ្រប់គ្រង

ប្រការ៥..

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាបញ្ជត្តិករក្នុងការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន។ ក្រសួងមាននាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាននៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុជាសេនាធិការ។

មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត បំពេញតួនាទី និងភារកិច្ចសម្របសម្រួល និងគាំទ្រការងារគ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្មទទួលបញ្ចាំ និង/ឬទទួលប្រាតិភោគដោយអនុប្បទានខ្នាតតូចនៅតាមរាជធានី-ខេត្ត ក្នុងនាមជាសេនាធិការរបស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ជំពូកទី៣
អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មទទួលបញ្ចាំ និង/ឬ ទទួលប្រាតិភោគដោយអនុប្បទាន

ប្រការ៦..

រាល់ការប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានខ្នាតមធ្យម និងខ្នាតធំត្រូវមានអាជ្ញាបណ្ណពីក្រសួង។ ដើម្បីទទួលបានអាជ្ញាបណ្ណក្រុមហ៊ុន/សហគ្រាសត្រូវដាក់ពាក្យស្នើសុំនៅនាយកដ្ឋានដោយបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- ជានីតិបុគ្គលសញ្ជាតិខ្មែរ និងបានចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់នៅព្រះរាជាណាចក្រកម្ពុជា (ចំពោះអាជីវកម្មខ្នាតធំកម្រិត២ត្រូវចុះបញ្ជីជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត)
- ត្រូវមានដើមទុនប្រកបអាជីវកម្មដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ
- ត្រូវតម្កល់ប្រាក់ធានាអាជីវកម្ម១0%នៃដើមទុន
- អ្នកកាន់អាជ្ញាបណ្ណត្រូវមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗទៀតដែលទាក់ទងនឹងអាជីវកម្ម ឬមានបទពិសោធន៍ពាក់ព័ន្ធទៅនឹងធុរៈកិច្ចស្រដៀងគ្នា ឬឆ្លាប់បម្រើការងារផ្នែកនេះ។ ក្នុងករណីអ្នកឈរឈ្មោះមិនមែនជាភាគហ៊ុនិកត្រូវមានលិខិតបញ្ជាក់ពីក្រសួងពាណិជ្ជកម្ម។

- ត្រូវមានទីតាំងប្រកបអាជីវកម្មច្បាស់លាស់ដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច។

លក្ខខណ្ឌលម្អិតសម្រាប់ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណត្រូវបានកំណត់ក្នុងពាក្យស្នើសុំអាជ្ញាបណ្ណរបស់ក្រសួង។

ប្រការ៧.-

រាល់ការប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានខ្នាតតូចត្រូវមានលិខិតអនុញ្ញាតប្រកបអាជីវកម្មពីមន្ទីរ។ ដើម្បីទទួលបានលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមហ៊ុន/សហគ្រាសត្រូវដាក់ពាក្យស្នើសុំនៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ដោយបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- ជានីតិបុគ្គលសញ្ជាតិខ្មែរ និងបានចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់នៅព្រះរាជាណាចក្រកម្ពុជា
- ត្រូវមានដើមទុនប្រកបអាជីវកម្មដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ
- ត្រូវតម្កល់ប្រាក់ធានាអាជីវកម្ម១០% នៃដើមទុន
- អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗ ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬមានបទពិសោធន៍ពាក់ព័ន្ធទៅនឹងធុរៈកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះ។ ក្នុងករណីអ្នកឈរឈ្មោះមិនមែនជាភាគហ៊ុននិកត្រូវមានលិខិតបញ្ជាក់ពីក្រសួងពាណិជ្ជកម្ម
- ត្រូវមានទីតាំងប្រកបអាជីវកម្មច្បាស់លាស់ដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច។

លក្ខខណ្ឌលម្អិតសម្រាប់ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវបានកំណត់ក្នុងពាក្យស្នើសុំរបស់មន្ទីរ។

ប្រការ៨.-

ក្រសួង/មន្ទីរមានរយៈពេលយ៉ាងយូរ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការក្នុងការពិនិត្យ និងសម្រេចផ្តល់ ឬបដិសេធ ឬបន្តសុពលភាពជូនក្រុមហ៊ុន/សហគ្រាសគិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារពេញលេញ និងគ្រប់ចំនួន។

ប្រការ៩.-

ដើមទុនសម្រាប់ប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានត្រូវបានកំណត់ដូចខាងក្រោម÷

ក- អាជីវកម្មទទួលបញ្ចាំរួមមាន÷

- ខ្នាតតូច ៖ត្រូវមានដើមទុនចាប់ពី ២០ លានរៀល ដល់ ៤០ លានរៀល
- ខ្នាតមធ្យម ៖ត្រូវមានដើមលើសពី ៤០ លានរៀល ដល់ ២០០ លានរៀល
- ខ្នាតធំ (កម្រិត១) ៖ត្រូវមានដើមទុនលើសពី ២០០ លានរៀល ដល់ ៨០០ លានរៀល
- ខ្នាតធំ (កម្រិត២) ៖ត្រូវមានដើមទុនលើសពី ៨០០ លានរៀល ឡើងទៅ

ខ- អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានរួមមាន÷

- ខ្នាតតូច ៖ត្រូវមានដើមទុនចាប់ពី ២០ លានរៀល ដល់ ៤០ លានរៀល
- ខ្នាតមធ្យម ៖ត្រូវមានដើមទុនលើសពី ៤០ លានរៀល ដល់ ២០០ លានរៀល
- ខ្នាតធំ (កម្រិត១) ៖ត្រូវមានដើមទុនលើសពី ២០០ លានរៀល ដល់ ៨០០ លានរៀល
- ខ្នាតធំ (កម្រិត២) ៖ត្រូវមានដើមទុនលើសពី ៨០០ លានរៀល ឡើងទៅ

រាល់ការបន្ថែម ឬបន្ថយដើមទុនអាជីវកម្មខាងលើត្រូវមានការអនុញ្ញាតពីក្រសួង/មន្ទីរជាមុន។

ប្រការ១០.-

ប្រភេទ ខ្នាត ថ្លៃ និងសុពលភាពអាជ្ញាបណ្ណប្រកបអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានដែលចេញដោយក្រសួងត្រូវបានកំណត់ដូចខាងក្រោម÷

ល.រ	ប្រភេទ		ថ្លៃអាជ្ញាបណ្ណថ្មី/បន្ត	សុពលភាព
-អាជីវកម្មទទួលបញ្ចាំ				
១	អាជ្ញាបណ្ណ	ខ្នាតមធ្យម	២.០០០.០០០រៀល/០១ឆ្នាំ	០៣ឆ្នាំ
		ខ្នាតធំ (កម្រិត១)	៣.០០០.០០០រៀល/០១ឆ្នាំ	
		ខ្នាតធំ (កម្រិត២)	៤.០០០.០០០រៀល/០១ឆ្នាំ	
២	អាជ្ញាបណ្ណសាខា	ខ្នាតមធ្យម	១.០០០.០០០រៀល/០១ឆ្នាំ	០៣ឆ្នាំ
		ខ្នាតធំ (កម្រិត១)	១.៥០០.០០០រៀល/០១ឆ្នាំ	
		ខ្នាតធំ (កម្រិត២)	២.០០០.០០០រៀល/០១ឆ្នាំ	
-អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន				
១	អាជ្ញាបណ្ណ	ខ្នាតមធ្យម	១.០០០.០០០រៀល/០១ឆ្នាំ	០៣ឆ្នាំ
		ខ្នាតធំ (កម្រិត១)	១.៥០០.០០០រៀល/០១ឆ្នាំ	
		ខ្នាតធំ (កម្រិត២)	២.០០០.០០០រៀល/០១ឆ្នាំ	
២	អាជ្ញាបណ្ណសាខា	ខ្នាតមធ្យម	៥០០.០០០រៀល/០១ឆ្នាំ	០៣ឆ្នាំ
		ខ្នាតធំ (កម្រិត១)	៧៥០.០០០រៀល/០១ឆ្នាំ	
		ខ្នាតធំ (កម្រិត២)	១.០០០.០០០រៀល/០១ឆ្នាំ	

ថ្លៃអាជ្ញាបណ្ណ ឬថ្លៃបន្តសុពលភាពអាជ្ញាបណ្ណដូចមានចែងក្នុងប្រការនេះត្រូវបង់រៀងរាល់០១ (មួយ) ឆ្នាំម្តងទៅក្នុងគណនីទោលរបស់រតនាគារជាតិដែលបើកនៅធនាគារជាតិ នៃកម្ពុជាតាមដីកាអមរបស់នាយកដ្ឋាន។

អ្នកកាន់អាជ្ញាបណ្ណត្រូវដាក់ពាក្យស្នើសុំបង់ថ្លៃបន្តសុពលភាពអាជ្ញាបណ្ណប្រចាំឆ្នាំឱ្យបាន៣០ ថ្ងៃមុន នៃឆ្នាំបន្ទាប់។

ប្រការ១១.

ប្រភេទ ថ្លៃ និងសុពលភាពលិខិតអនុញ្ញាតប្រកបអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានខ្នាតតូច ដែលចេញដោយមន្ទីរត្រូវបានកំណត់ដូចខាងក្រោម÷

ល.រ	ប្រភេទ		ថ្លៃលិខិតអនុញ្ញាតថ្មី/ បន្ត	សុពលភាព
-អាជីវកម្មទទួលបញ្ចាំ				
១	លិខិតអនុញ្ញាត	ខ្នាតតូច	១.០០០.០០០រៀល	០១ឆ្នាំ
២	លិខិតអនុញ្ញាតសាខា	ខ្នាតតូច	៥០០.០០០រៀល	០១ឆ្នាំ
-អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន				
១	លិខិតអនុញ្ញាត	ខ្នាតតូច	៥០០.០០០រៀល	០១ឆ្នាំ
២	លិខិតអនុញ្ញាតសាខា	ខ្នាតតូច	២៥០.០០០រៀល	០១ឆ្នាំ

ថ្លៃលិខិតអនុញ្ញាតប្រកបអាជីវកម្មដូចមានចែងក្នុងប្រការនេះ ត្រូវបង់ចូលគណនីទោលរបស់សាខារតនាគារជាតិ ដែលបើកនៅសាខាធនាគារជាតិ នៃកម្ពុជានៅបណ្តារាជធានី-ខេត្ត តាមដីកាអមរបស់មន្ទីរសាមីរាជធានី-ខេត្ត នោះ។

អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតឱ្យបាន ៣០ ថ្ងៃមុនលិខិតអនុញ្ញាតនោះផុតសុពលភាព និងត្រូវបង់ថ្លៃបន្តសុពលភាពដូចមានចែងក្នុងប្រការនេះ។

ប្រការ១២.-

ក្រុមហ៊ុន/សហគ្រាស អាចបង្កើតសាខាបានលុះត្រាតែមានអាជ្ញាបណ្ណពីក្រសួង/លិខិតអនុញ្ញាតប្រកបអាជីវកម្មពីមន្ទីរ។

ដើម្បីបើកសាខាបានក្រុមហ៊ុន/សហគ្រាសត្រូវបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ៦ និងប្រការ ៧នៃប្រកាសនេះ។

ជំពូកទី៤
កិច្ចដំណើរការអាជីវកម្មទទួលបញ្ជាំ និងទទួលប្រាតិភោគដោយអនុប្បទាន
ផ្នែកទី១
ភាគព្វកិច្ចរបស់អ្នកកាន់អាជ្ញាបណ្ណ និងអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម

ប្រការ១៣.-

អ្នកកាន់អាជ្ញាបណ្ណ និងអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មមានភាគព្វកិច្ចដូចខាងក្រោម÷

- ត្រូវទទួលខុសត្រូវចំពោះអតិថិជនដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់ខ្លួន
- ត្រូវមានស្លាកយីហោអាជីវកម្មនៅពីមុខកន្លែងធ្វើអាជីវកម្ម ហើយអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវដាក់បង្ហាញនៅកន្លែងដែលងាយមើលឃើញ
- ត្រូវធ្វើអាជីវកម្មឱ្យបានត្រឹមត្រូវស្របតាមឈ្មោះ អាសយដ្ឋានដែលបានបញ្ជាក់នៅក្នុងអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ត្រូវមានកិច្ចសន្យា និងសៀវភៅកត់ត្រាប្រតិបត្តិការអាជីវកម្មទទួលបញ្ចាំ ឬទទួលប្រាតិភោគដោយអនុប្បទាន និងត្រូវថែរក្សាទុកដាក់ឱ្យបានល្អ។ ទម្រង់កិច្ចសន្យា និងសៀវភៅកត់ត្រាប្រតិបត្តការអាជីវកម្មនឹងមានផ្តល់ជូនដោយក្រសួង
- រាល់កិច្ចសន្យាដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទានត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជាមួយអតិថិជនព្រមទាំងមានការបញ្ជាក់ឱ្យបានច្បាស់លាស់នូវព័ត៌មានអប្បរមា លក្ខខណ្ឌ រយៈពេលកិច្ចសន្យាដូចមានចែងក្នុងកថាខណ្ឌទី២ នៃប្រការ១៦ និងភាគព្វកិច្ចដែលគូភាគីបានព្រមព្រៀងគ្នាដោយមានការចុះហត្ថលេខា ឬស្នាមមេដៃទទួលស្គាល់ត្រឹមត្រូវដោយគូភាគីនៃកិច្ចសន្យា
- ត្រូវរក្សាទុកទ្រព្យបញ្ចាំ និង/ឬប្រាតិភោគដោយអនុប្បទាននៅកន្លែងដែលមានសុវត្ថិភាព និងមិនត្រូវយកទ្រព្យនោះទៅប្រើប្រាស់ឡើយ
- ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការខូចខាត ឬបាត់បង់លើទ្រព្យបញ្ចាំ ឬទ្រព្យប្រាតិភោគដោយអនុប្បទានកើតឡើងក្នុងអំឡុងពេលជាប់កិច្ចសន្យា
- ត្រូវផ្តល់ព័ត៌មានជាបន្ទាន់ឱ្យនគរបាល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលមានទីតាំងនៅជិតកន្លែងអាជីវកម្មក្នុងករណីមានការសង្ស័យចំពោះអតិថិជន ឬទ្រព្យណាមួយដែលពាក់ព័ន្ធនឹងបទល្មើស
- ត្រូវផ្តល់ព័ត៌មាន ឬរាយការណ៍អំពីអត្តសញ្ញាណនៃអតិថិជន និងទ្រព្យ (សៀវភៅចុះបញ្ជីទ្រព្យ) ជូនប៉ុស្តិ៍នគរបាលរដ្ឋបាល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលមានទីតាំងនៅជិតកន្លែងអាជីវកម្មក្នុងរយៈពេល០៧ (ប្រាំពីរ)ថ្ងៃយ៉ាងយូរបន្ទាប់ពីកាលបរិច្ឆេទទទួលទ្រព្យបញ្ចាំ និង/ឬទ្រព្យប្រាតិភោគដោយអនុប្បទាន
- ត្រូវធានាថារាល់ការផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុន/សហគ្រាសត្រូវតែជាការពិត និងមានការបញ្ជាក់ពីអត្ត-លេខក្រុមហ៊ុន/សហគ្រាស

- ត្រូវបិទផ្សាយថ្ងៃ និងពេលវេលាម៉ោងធ្វើការរបស់ខ្លួននៅមុខច្រកទ្វារចេញ-ចូលនៃកន្លែងអាជីវកម្មឱ្យបានត្រឹមត្រូវ និងមិនត្រូវមានប្រតិបត្តិការទទួលបញ្ចាំ ឬទទួលប្រាតិភោគដោយអនុប្បទាន និងប្រមូលការប្រាក់ឡើយក្រៅពីថ្ងៃ ឬម៉ោងដែលបានប្រកាសបិទមិនធ្វើការ
- ត្រូវផ្តល់របាយការណ៍ឱ្យបានទៀងទាត់ដូចមានចែងក្នុងប្រការ២៩នៃប្រកាសនេះ ដោយត្រូវបញ្ជាក់ថាពិតជាត្រឹមត្រូវដោយនាយកក្រុមហ៊ុន/សហគ្រាស
- ត្រូវបំពេញកាតព្វកិច្ចពន្ធដារឱ្យបានត្រឹមត្រូវដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ
- ត្រូវរាយការណ៍ជាបន្ទាន់ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជានៃធនាគារជាតិនៃកម្ពុជា ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ឬមកក្រសួង/មន្ទីរក្នុងករណីសង្កេតឃើញសកម្មភាពណាមួយដែលបម្រើដល់ការលាងសម្អាតប្រាក់ ឬបម្រើផលប្រយោជន៍ដល់ភេរវករ ឬបទល្មើសភេរវកម្មណាមួយ
- ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលនៅជាធរមាន។

ប្រការ១៤.-

ក្រុមហ៊ុន/សហគ្រាសត្រូវបានហាមឃាត់សកម្មភាពអាជីវកម្មមួយចំនួនដូចខាងក្រោម÷

- មិនត្រូវផ្សព្វផ្សាយពាណិជ្ជកម្មដែលមានលក្ខណៈមិនពិត ឬឆបោក ឬនាំឱ្យមានការយល់ខុស ឬធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍សាធារណៈ
- មិនត្រូវទទួលយកទ្រព្យអ្វីមួយពីអនីតិជន ឬពីជនណាមួយដែលកំពុងឋិតក្នុងភាពស្រវឹងជោគជាំ ជនវិប្បលាសស្មារតី ឬពីជនណាមួយដែលសង្ស័យថាជាចោរ ឬអ្នកទទួលផលចោរកម្ម
- មិនត្រូវបង្កវាទប្បជិវាទក្នុងការធ្វើអាជីវកម្មជាមួយអ្នកទទួលបញ្ចាំ ឬប្រាតិភោគដោយអនុប្បទានដទៃទៀត
- មិនត្រូវចូលរួម ឬធ្វើអាជីវកម្ម ដើម្បីបម្រើដល់សកម្មភាពលាងសម្អាតប្រាក់ឬបម្រើផលប្រយោជន៍ដល់ភេរវករ ឬឧក្រិដ្ឋជនណាមួយឡើយ
- មិនត្រូវទទួលយកទ្រព្យបញ្ចាំ ឬទ្រព្យប្រាតិភោគដោយអនុប្បទានណាដែលពុំមានឯកសារ ឬលិខិតបញ្ជាក់អត្តសញ្ញាណទ្រព្យច្បាស់លាស់
- មិនត្រូវធ្វើអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មទទួលបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន
- មិនត្រូវទទួលយកទ្រព្យណាមួយដែលច្បាប់ហាមឃាត់។

ផ្នែកទី ២
ការផ្តល់ប្រាក់កម្ចី

ប្រការ១៥.-

ចំពោះក្រុមហ៊ុន/សហគ្រាស ដែលទទួលបានអាជ្ញាបណ្ណពីក្រសួង ការផ្តល់ប្រាក់កម្ចីដល់អ្នកដាក់បញ្ចាំ ឬដល់អ្នកដាក់ប្រាតិភោគដោយអនុប្បទាន ០១ ប្រតិបត្តិការមិនត្រូវលើសពី ២០ % (ម្ភៃភាគរយ) នៃដើមទុនអាជីវកម្មដែលបានប្រកាសឡើយ។ ការផ្តល់ប្រាក់កម្ចីសម្រាប់ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុមិនត្រូវលើសពី ២០.០០០.០០០ (ម្ភៃលាន) រៀលឡើយក្នុងមួយប្រតិបត្តិការនៃទ្រព្យបញ្ចាំ។

ចំពោះក្រុមហ៊ុន/សហគ្រាស ដែលទទួលបានលិខិតអនុញ្ញាតប្រកបអាជីវកម្មពីមន្ទីរ ការផ្តល់ប្រាក់កម្ចីដល់អ្នកដាក់បញ្ចាំ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទាន ០១ ប្រតិបត្តិការមិនត្រូវលើសពី ២០ % (ម្ភៃភាគរយ) នៃដើមទុនអាជីវកម្មដែលបានប្រកាសឡើយ។ ការផ្តល់ប្រាក់កម្ចីសម្រាប់ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុមិនត្រូវលើសពី ៤.០០០.០០០ (បួនលាន) រៀលក្នុងមួយប្រតិបត្តិការនៃទ្រព្យបញ្ចាំនោះ។

ផ្នែកទី ៣
អត្រាការប្រាក់ និងរយៈពេលនៃការជាក់បញ្ចាំ និង/ឬប្រាតិភោគដោយអនុប្បទាន

ប្រការ១៦.-

អត្រាការប្រាក់ត្រូវកំណត់តាមការព្រមព្រៀងរវាងអ្នកទទួលបញ្ចាំ ឬអ្នកទទួលប្រាតិភោគដោយអនុប្បទាន និងអ្នកជាក់បញ្ចាំ ឬអ្នកជាក់ប្រាតិភោគដោយអនុប្បទាន និងត្រូវអនុលោមតាមបទប្បញ្ញត្តិ និងច្បាប់ដែលនៅជាធរមាន។

កិច្ចសន្យានេះមានសុពលភាពអនុវត្តយ៉ាងយូរត្រឹម០៤ (បួន) ខែ ចាប់ពីកាលបរិច្ឆេទនៃការជាក់ទ្រព្យបញ្ចាំ ឬជាក់ទ្រព្យប្រាតិភោគដោយអនុប្បទាន និងអាចបន្តសុពលភាពសារជាថ្មីបាន។

ផ្នែកទី ៤
ការចាត់ចែងទ្រព្យ

ប្រការ១៧.-

ក្នុងករណីអ្នកជាក់បញ្ចាំ ឬអ្នកជាក់ប្រាតិភោគដោយអនុប្បទានបានសងប្រាក់កម្ចី និងការប្រាក់គ្រប់ចំនួនដូចមានចែងក្នុងកិច្ចសន្យាក្រុមហ៊ុន/សហគ្រាសត្រូវប្រគល់ទ្រព្យបញ្ចាំ ឬទ្រព្យប្រាតិភោគដោយអនុប្បទានទៅឱ្យអ្នកជាក់បញ្ចាំ ឬអ្នកជាក់ប្រាតិភោគដោយអនុប្បទានវិញភ្លាម។

ប្រការ១៨.-

ក្រុមហ៊ុន/សហគ្រាស ពុំមានសិទ្ធិលក់ ផ្ទេរ ប្រើប្រាស់ ឬប្រគល់សិទ្ធិកាន់កាប់ទ្រព្យបញ្ចាំ ឬទ្រព្យប្រាតិភោគ-ដោយអនុប្បទាន ឱ្យទៅបុគ្គលផ្សេងទៀតក្នុងអំឡុងពេលដែលទ្រព្យបញ្ចាំ ឬទ្រព្យប្រាតិភោគដោយអនុប្បទាននោះកំពុងជាប់កិច្ចសន្យា ដោយពុំមានការឯកភាពពីអ្នកជាក់បញ្ចាំ ឬអ្នកជាក់ប្រាតិភោគដោយអនុប្បទានឡើយ។

ប្រការ១៩.-

ក្នុងករណីអ្នកជាក់បញ្ចាំ ឬអ្នកជាក់ប្រាតិភោគដោយអនុប្បទានពុំមានលទ្ធភាពសងប្រាក់កម្ចីនិងការប្រាក់តាមការកំណត់នៅពេលកិច្ចសន្យាដល់កាលវិសាន្តការចាត់ចែងលើទ្រព្យបញ្ចាំ ឬទ្រព្យប្រាតិភោគដោយអនុប្បទានមានដូចខាងក្រោម÷

- **សម្រាប់អាជីវកម្មទទួលបញ្ចាំ÷** ទ្រព្យបញ្ចាំត្រូវចាត់ចែងអនុលោមតាមនីតិវិធីដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។
- **សម្រាប់អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន÷** ទ្រព្យប្រាតិភោគដោយអនុប្បទាននឹងត្រូវចាត់ចែងតាមលទ្ធភាពជាក់ស្តែង ឬនីតិវិធីដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ផ្នែកទី៥
ការផ្លាស់ប្តូរទីតាំង នាមករណ៍ ភាគទុននិក សមាជិកក្រុមប្រឹក្សាភិបាល អ្នកកាន់អាជ្ញាបណ្ណ ឬអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម

ប្រការ២០.-

រាល់ការផ្លាស់ប្តូរទីតាំងអាជីវកម្ម នាមករណ៍ ភាគទុននិក សមាជិកក្រុមប្រឹក្សាភិបាល អ្នកកាន់អាជ្ញាបណ្ណ ឬអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវមានការឯកភាពជាមុនពីក្រសួង/មន្ទីរ។

ក្រុមហ៊ុន/សហគ្រាសត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរមុននឹងធ្វើការផ្លាស់ប្តូរ។

ក្រសួង ឬមន្ទីរ ត្រូវជូនដំណឹងអំពីការសម្រេចឯកភាព ឬជំទាស់ ក្នុងរយៈពេល ៣០ ថ្ងៃនៃថ្ងៃធ្វើការ ឬរយៈពេលសមស្របណាមួយ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលសំណើ។

ច្បាប់ការ២១.-

ការផ្លាស់ប្តូរទីតាំងអាជីវកម្ម នាមករណ៍ ភាគទុនិក សមាជិកក្រុមប្រឹក្សាភិបាល អ្នកកាន់អាជ្ញាបណ្ណ ឬអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មរបស់ក្រុមហ៊ុន/សហគ្រាសត្រូវផ្តល់ឯកសារដូចខាងក្រោម÷

ក. ការស្នើសុំផ្លាស់ប្តូរទីតាំងអាជីវកម្មរបស់ក្រុមហ៊ុន/សហគ្រាស÷

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរស្តីពីការស្នើសុំផ្លាស់ប្តូរដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- លិខិតឯកភាពពីអាជ្ញាធរដែនដីចំពោះទីតាំងអាជីវកម្មថ្មី
- លិខិតបញ្ជាក់ស្តីពីការបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវតាមច្បាប់ស្តីពីសារពើពន្ធ
- ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុទីតាំងថ្មី ឬកិច្ចសន្យាជួលទីតាំងថ្មី
- ឯកសារបញ្ជាក់ពីការចុះផ្សាយលើទំព័រសារព័ត៌មានក្នុងស្រុកណាមួយដោយទុកឱ្យរយៈពេលយ៉ាងតិច០១ ខែគិតចាប់ពីកាលបរិច្ឆេទនៃការចុះផ្សាយ ដើម្បីឱ្យអតិថិជនបានជ្រាបអំពីការផ្លាស់ប្តូរទីតាំងអាជីវកម្ម និងជម្រះបញ្ជីប្រតិបត្តិការជាមួយអតិថិជនឱ្យបានរួចរាល់

ខ. ការស្នើសុំផ្លាស់ប្តូរនាមករណ៍របស់ក្រុមហ៊ុន/សហគ្រាស÷

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរស្តីពីការស្នើសុំផ្លាស់ប្តូរនាមករណ៍ដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្តីពីការផ្លាស់ប្តូរនាមករណ៍ ឬលិខិតសម្រេចរបស់នាយកក្រុមហ៊ុន/សហគ្រាស
- ឯកសារបញ្ជាក់ពីការចុះផ្សាយលើទំព័រសារព័ត៌មានក្នុងស្រុកណាមួយដោយទុកឱ្យរយៈពេលយ៉ាងតិច០១ ខែគិតចាប់ពីកាលបរិច្ឆេទនៃការចុះផ្សាយ ដើម្បីឱ្យអតិថិជនបានជ្រាបអំពីការផ្លាស់ប្តូរនាមករណ៍

គ. ការស្នើសុំផ្លាស់ប្តូរភាគទុនិក ឬសមាជិកក្រុមប្រឹក្សាភិបាលប្រកបអាជីវកម្ម÷

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរ ស្តីពីការស្នើសុំផ្លាស់ប្តូរភាគទុនិក ឬសមាជិកក្រុមប្រឹក្សាភិបាលដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្តីពីការផ្លាស់ប្តូរភាគទុនិក ឬសមាជិកក្រុមប្រឹក្សាភិបាល
- លិខិតទិញ-លក់ភាគហ៊ុនរបស់ភាគហ៊ុនិក
- លិខិតថ្កោលទោសឬលិខិតបញ្ជាក់កិរិយាមារយាទចេញដោយអាជ្ញាធរមានសមត្ថកិច្ច

ឃ. ការស្នើសុំផ្លាស់ប្តូរអ្នកកាន់អាជ្ញាបណ្ណ/អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម÷

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរ ស្តីពីការស្នើសុំផ្លាស់ប្តូរដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- អាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មច្បាប់ដើម
- សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗ ឬលិខិតបញ្ជាក់បទពិសោធន៍ពាក់ព័ន្ធធុរៈកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះចំពោះអ្នកកាន់អាជ្ញាបណ្ណ។
- សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗ ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬលិខិតបញ្ជាក់បទ-ពិសោធន៍ពាក់ព័ន្ធធុរៈកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះ ចំពោះអ្នកកាន់លិខិតអនុញ្ញាតប្រកប-អាជីវកម្ម
- លិខិតថ្កោលទោស ឬលិខិតបញ្ជាក់កិរិយាមាយាទចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

ផ្នែកទី ៦
ប្រាក់តម្កល់ធានាអាជីវកម្ម

ប្រការ២២.-

ក្រុមហ៊ុន/សហគ្រាស ខ្នាតមធ្យម និងខ្នាតធំត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១០ % (ដប់ភាគរយ) នៃដើមទុនប្រកបអាជីវកម្មទៅក្នុងគណនីទោលរតនាគារជាតិដែលបើកនៅធនាគារជាតិ នៃកម្ពុជាតាមដីកាអមរបស់នាយកដ្ឋាន។

ក្រុមហ៊ុន/សហគ្រាសខ្នាតតូច ត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១០% (ដប់ភាគរយ) នៃដើមទុនប្រកបអាជីវកម្មទៅក្នុងគណនីទោលរបស់សាខារតនាគារជាតិ ដែលបើកនៅសាខាធនាគារជាតិនៃកម្ពុជាតាមដីកាអមរបស់មន្ទីរសាមីនោះ។

ប្រាក់តម្កល់ធានាអាជីវកម្មដូចមានចែងក្នុងកថាខណ្ឌទី១ និងទី២ ខាងលើអាចដកវិញបានក្រោយពីក្រុមហ៊ុន/សហគ្រាសបានបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ ហើយត្រូវគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ២៥ ។

ប្រការ២៣.-

នៅក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃបានទទួលលិខិតស្នើសុំដកប្រាក់តម្កល់និងឯកសារតម្រូវផ្សេងៗ ក្រសួងត្រូវចេញលិខិតអនុញ្ញាតឱ្យដក ឬលិខិតបដិសេធដកប្រាក់តម្កល់នោះ ដោយបញ្ជាក់ហេតុផលត្រឹមត្រូវ។

ជំពូកទី ៥
ការផ្អាក និងការបញ្ឈប់សកម្មភាពអាជីវកម្ម

ប្រការ២៤.-

ក្នុងករណីផ្អាកសកម្មភាពអាជីវកម្ម ក្រុមហ៊ុន/សហគ្រាសត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរ ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធដូចខាងក្រោម÷

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរស្តីពីការស្នើសុំផ្អាកដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- លិខិតបញ្ជាក់ស្តីពីការបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវតាមច្បាប់សារពើពន្ធ
- លិខិតជូនដំណឹងទៅអាជ្ញាធរពន្ធដារមានសមត្ថកិច្ចស្តីពីការផ្អាកសកម្មភាពអាជីវកម្ម
- ឯកសារពាក់ព័ន្ធការជម្រះបញ្ជីជាមួយអតិថិជនដែលដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទាន

ក្រសួង/មន្ទីរអនុញ្ញាតឱ្យ ក្រុមហ៊ុន/សហគ្រាសផ្អាកសកម្មភាពអាជីវកម្មរបស់ខ្លួនជាបណ្តោះអាសន្នយ៉ាងយូរត្រឹម៤ (បួន) ខែ ក្នុង១ (មួយ) ឆ្នាំ ឬត្រឹមសុពលភាពអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មដែលនៅសល់តែប៉ុណ្ណោះ។

ប្រការ២៥.-

ក្នុងករណីបញ្ឈប់សកម្មភាពអាជីវកម្ម ក្រុមហ៊ុន/សហគ្រាសត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរ មុនបញ្ឈប់សកម្មភាពអាជីវកម្ម និងត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារដូចខាងក្រោម÷

- លិខិតស្នើសុំបញ្ឈប់អាជីវកម្មដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់
- អាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មច្បាប់ដើម
- លិខិតបញ្ជាក់ពីការបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវដែលចេញដោយអាជ្ញាធរពន្ធដារមានសមត្ថកិច្ច
- ឯកសារពាក់ព័ន្ធការចុះផ្សាយលើទំព័រសារព័ត៌មានក្នុងស្រុកណាមួយដោយទុករយៈពេលយ៉ាតតិច០១ ខែគិតចាប់ពីកាលបរិច្ឆេទនៃការចុះផ្សាយ ដើម្បីឱ្យអតិថិជនបានជ្រាបអំពីការបញ្ឈប់សកម្មភាពអាជីវកម្ម និងការជម្រះបញ្ជីប្រតិបត្តិការជាមួយអតិថិជន
- បង្កាន់ដៃបង់ប្រាក់តម្កល់ធានាអាជីវកម្ម។

ប្រការ២៦.-

នៅក្នុងរយៈពេលយ៉ាងយូរ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃបានទទួលលិខិតស្នើសុំផ្អាក ឬបញ្ឈប់សកម្មភាពអាជីវកម្ម ឯកសារតម្រូវផ្សេងៗក្រសួង/មន្ទីរ ត្រូវចេញលិខិតបញ្ជាក់យល់ព្រម ឬបដិសេធសំណើរបស់ក្រុមហ៊ុន/សហគ្រាសដោយបញ្ជាក់ហេតុផលត្រឹមត្រូវ។

ជំពូកទី៦
ការត្រួតពិនិត្យ និងរបាយការណ៍

ប្រការ២៧.-

ក្រសួង/មន្ទីរមានសិទ្ធិចាត់មន្ត្រីជំនាញចុះត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងដើម្បីធានាដល់ការអនុវត្តប្រកាសនេះ។

ប្រការ២៨.-

មន្ទីរត្រូវផ្តល់ជូននាយកដ្ឋាននូវរបាយការណ៍ដូចខាងក្រោម÷

-របាយការណ៍ប្រចាំត្រីមាសស្តីពីសកម្មភាពអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានឱ្យបានមុនថ្ងៃទី១៥ នៃត្រីមាសបន្ទាប់

-របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុន/សហគ្រាសទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានឱ្យបានមុនបំណាច់ត្រីមាសទី១ នៃឆ្នាំសារពើពន្ធ។

ទម្រង់នៃរបាយការណ៍ខាងលើត្រូវបានកំណត់ទៅតាមគំរូដែលនាយកដ្ឋានបានផ្តល់ជូន។

ប្រការ២៩.-

ក្រុមហ៊ុន/សហគ្រាសដែលទទួលបានអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវផ្តល់ជូនក្រសួង/មន្ទីរនូវរបាយការណ៍ដូចខាងក្រោម÷

- របាយការណ៍ប្រតិបត្តិការអាជីវកម្មប្រចាំខែមិនឱ្យលើសពីថ្ងៃទី១៥ នៃខែបន្ទាប់
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមិនឱ្យលើសពីត្រីមាសទី១ នៃឆ្នាំបន្ទាប់

ទម្រង់នៃរបាយការណ៍ខាងលើត្រូវបានកំណត់តាមគំរូដែលកំណត់ដោយក្រសួង។

ប្រការ៣០.-

ក្រសួង/មន្ទីរមានសិទ្ធិតែងតាំងសវនករឯករាជ្យ ដើម្បីធ្វើសវនកម្មក្រុមហ៊ុន/សហគ្រាសទាំងអស់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ក្នុងករណីរកឃើញភាពមិនប្រក្រតីលើឯកសារពាក់ព័ន្ធនឹងប្រតិបត្តិការអាជីវកម្មដែលផ្តល់ដោយក្រុមហ៊ុន/សហគ្រាស ដោយរាល់ការចំណាយលើសវនករឯករាជ្យជាបន្ទុករបស់ក្រុមហ៊ុន/សហគ្រាស។

ជំពូកទី៧
ការផ្សះផ្សា និងដោះស្រាយវិវាទ

ប្រការ៣១.-

វិវាទរវាងក្រុមហ៊ុន/សហគ្រាសទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានជាមួយក្រុមហ៊ុន/សហគ្រាសទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន និង/ឬជាមួយអ្នកជាក់បញ្ចាំ/អ្នកជាក់ប្រាតិភោគដោយអនុប្បទានពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មបញ្ចាំ ឬប្រាតិភោគដោយអនុប្បទានអាចជាកម្មវត្ថុនៃការសម្រុះសម្រួល និងផ្សះផ្សាដោយអគ្គនាយកដ្ឋាន/មន្ទីរ។

ក្រសួង/មន្ទីរសម្រុះសម្រួល និងផ្សះផ្សាវិវាទតាមការស្នើសុំរបស់ភាគីវិវាទក្នុងរយៈពេល០២ខែយ៉ាងយូរ។ ការផ្សះផ្សាវិវាទអាចឈានទៅដល់ការចុះកិច្ចព្រមព្រៀងផ្សះផ្សា ដែលត្រូវចុះហត្ថលេខាដោយតួភាគីវិវាទដោយមានប្រថាប់ត្រារបស់អគ្គនាយកដ្ឋាន/មន្ទីរ។ កិច្ចព្រមព្រៀងផ្សះផ្សាមានអានុភាពអនុវត្តភ្លាមៗចំពោះតួភាគី។

ប្រការ៣២.-

ក្រុមហ៊ុន/សហគ្រាស ឬអ្នកដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទានដែលមិនពេញចិត្តចំពោះសេចក្តីសម្រេច ឬវិធានការផ្សេងៗរបស់ក្រសួង/មន្ទីរមានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ាមកក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មុននឹងអនុវត្តនីតិវិធីបណ្តឹងទៅតុលាការលើកលែងតែរឿងព្រហ្មទណ្ឌ។

ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវដោះស្រាយបណ្តឹងក្នុងរយៈពេល៩០ ថ្ងៃនៃថ្ងៃធ្វើការក្រោយពីទទួលបានពាក្យបណ្តឹងតវ៉ា ឬក្នុងរយៈពេលមួយសមស្រប។

ក្នុងការដោះស្រាយវិវាទក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចអញ្ជើញភាគីពាក់ព័ន្ធវិវាទដើម្បីសាកសួរ ឬផ្តល់កស្តុតាងតាមការចាំបាច់។

សេចក្តីសម្រេច ស្តីពីការដោះស្រាយវិវាទត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយមានបញ្ជាក់អំពីអង្គហេតុសំអាងហេតុ និងការសន្និដ្ឋាន។

ក្នុងករណីមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សានីតិកម្ម ភាគីវិវាទអាចដាក់ពាក្យបណ្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

ជំពូកទី៨
ទោសប្បញ្ញត្តិ

ប្រការ៣៣.-

ត្រូវបានចាត់ទុកជាអំពើបំពាននឹងបទប្បញ្ញត្តិនៃប្រកាសនេះចំពោះអំពើដូចខាងក្រោម÷

- ប្រកបអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន គ្មានអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ក្លែងបន្លំអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ប្រើប្រាស់អាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មផុតសុពលភាព
- ប្រកបអាជីវកម្មខុសពីទីតាំងដែលបានបញ្ជាក់នៅលើអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ផ្តល់ប្រាក់កម្ចីខុសពីលក្ខខណ្ឌដូចមានចែងក្នុងប្រការ១៥ នៃប្រកាសនេះ
- យឺតយ៉ាវក្នុងការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃមុនពេលអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មនោះផុតសុពលភាព
- បង្កើតសាខាដោយគ្មានការអនុញ្ញាតពីក្រសួង/មន្ទីរ
- ប្រកបអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មដែលបានផ្តល់ជូន
- អនុវត្តផ្ទុយនឹងប្រការ១៣ ប្រការ១៤ ប្រការ១៥ ប្រការ២០ ប្រការ២៤ និងប្រការ២៥ នៃប្រកាសនេះ
- មិនបានផ្តល់ ឬផ្តល់របាយការណ៍យឺតយ៉ាវតាមការកំណត់ដូចមានចែងក្នុងប្រការ២៩ នៃប្រកាសនេះ
- ពុំអនុវត្តតាមការណែនាំជាលាយលក្ខណ៍អក្សររបស់ក្រសួង។

ប្រការ៣៤.-

ក្រុមហ៊ុន/សហគ្រាសទាំងឡាយណាដែលបានប្រព្រឹត្តកំហុសដូចមានចែងក្នុងប្រការ៣៣នៃប្រកាសនេះនឹងត្រូវទទួលរងទណ្ឌកម្មរដ្ឋបាលដូចខាងក្រោម÷

- ព្រមានជាលាយលក្ខណ៍អក្សរ
- ហាមឃាត់ការធ្វើប្រតិបត្តិការឬរឹតត្បិតសកម្មភាពមួយចំនួន
- ព្យួរអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មបណ្តោះអាសន្នពី០៦ ខែទៅ១ ឆ្នាំ
- ដកហូតអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ផ្សព្វផ្សាយជាសាធារណៈនូវអំពើបំពាននឹងបទប្បញ្ញត្តិនៃប្រកាសនេះ

- ចាត់វិធានការផ្សេងៗទៀតទៅតាមច្បាប់ជាធរមាន។

ប្រការ៣៥.

ក្រសួង/មន្ទីរមានសិទ្ធិព្យួរអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មនៅពេលដែលក្រុមហ៊ុន/សហគ្រាសបានប្រព្រឹត្តល្មើសក្នុងករណីណាមួយដូចខាងក្រោម÷

- ខកខានមិនបានផ្តល់របាយការណ៍ប្រចាំខែដោយចេតនា ឬអចេតនាក្រោយពីទទួលបានការព្រមានជាលាយលក្ខណ៍អក្សរ
- បង្កើតសាខាដោយគ្មានការអនុញ្ញាតពីក្រសួង/មន្ទីរជាមុន
- ប្រកបអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មដែលបានផ្តល់ជូនដោយចេតនាក្រោយពីទទួលការព្រមានជាលាយលក្ខណ៍អក្សរ
- បន្តអនុវត្តផ្ទុយនឹងប្រការ១៣ ប្រការ១៤ ប្រការ១៥ ប្រការ២០ ប្រការ២៤ និងប្រការ២៥ នៃប្រកាសនេះក្រោយពីទទួលបានលិខិតព្រមានជាលាយលក្ខណ៍អក្សរ។

ប្រការ៣៦.

ក្រសួង/មន្ទីរ មានសិទ្ធិដកហូតអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មនៅពេលដែលក្រុមហ៊ុន/សហគ្រាសបានប្រព្រឹត្តល្មើសក្នុងករណីណាមួយដូចខាងក្រោម÷

- ខកខានមិនបានផ្តល់របាយការណ៍ប្រចាំខែដោយចេតនា ឬអចេតនាចាប់ពី០៦ ខែឡើងទៅ
- ក្រោយពីទទួលការព្រមានជាលាយលក្ខណ៍អក្សរលើកទី២ ហើយនៅតែមិនរៀងចាលទៀត
- ខកខានមិនបានបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវតាមច្បាប់ស្តីពីសារពើពន្ធលើសពី០៦ ខែឡើងទៅ
- ប្រើប្រាស់អាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មផុតសុពលភាពលើសពី០៣ ខែឡើងទៅ
- ក្រោយពីទទួលការព្រមានជាលាយលក្ខណ៍អក្សរ ហើយនៅតែបន្តប្រកបអាជីវកម្មខុសពីទីតាំងដែលបានបញ្ជាក់នៅលើអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មទៀត
- ផ្តល់ប្រាក់កម្ចីខុសពីលក្ខខណ្ឌដូចមានចែងក្នុងប្រការ១៥ នៃប្រកាសនេះលើសពី០៥ ករណីឡើងទៅ
- យឺតយ៉ាវក្នុងការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មលើសពី០៣ ខែ ក្រោយពេលអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មនោះផុតសុពលភាព
- បង្កើតសាខាលើសពី០២ (ពីរ) សាខាឡើងទៅដោយគ្មានការអនុញ្ញាតពីក្រសួង/មន្ទីរជាមុន
- ធ្វើអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម ដែលបានផ្តល់ជូនដោយចេតនាក្រោយពីទទួលការព្រមានជាលាយលក្ខណ៍អក្សរលើកទី២ហើយ
- នៅបន្តអនុវត្តផ្ទុយនឹងប្រការ១៣ ប្រការ១៧ ប្រការ១៩ និងប្រការ២៥ នៃប្រកាសនេះក្រោយពីអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវបានព្យួរហើយ
- បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬប្រព្រឹត្តបទល្មើសហិរញ្ញវត្ថុ ឬអំពើមិនស្របច្បាប់ណាមួយដែលមានភស្តុតាងច្បាស់លាស់ពីអាជ្ញាធរមានសមត្ថកិច្ច។

ក្រសួង/មន្ទីរ នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរចំនួន៣០ (សាមសិប) ថ្ងៃមុននឹងដកហូតអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មពីក្រុមហ៊ុន/សហគ្រាសដែលបានប្រព្រឹត្តខុស។

ប្រការ៣៧.

ការប្រកបអាជីវកម្មទទួលបញ្ចាំ/ទទួលប្រាតិភោគដោយអនុប្បទានដោយគ្មានអាជ្ញាបណ្ណ ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន១០.០០០.០០០ (ដប់លាន)រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។ ដើម្បីអាចប្រកបអាជីវកម្មបាន ក្រុមហ៊ុន/សហគ្រាសត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមកក្រសួង។

ការប្រកបអាជីវកម្មទទួលបញ្ចាំ/ទទួលប្រាតិភោគដោយអនុប្បទាន ដោយគ្មានលិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន ៥.០០០.០០០ (ប្រាំលាន)រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។ ដើម្បីអាចប្រកបអាជីវកម្មបានក្រុមហ៊ុន/សហគ្រាសត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មមកមន្ទីរ។

ប្រការ៣៨.

ការក្លែងបន្លំអាជ្ញាបណ្ណត្រូវទទួលពិន័យអន្តរការណ៍ចំនួន ១០.០០០.០០០ (ដប់លាន) រៀល និងបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។

ការក្លែងបន្លំលិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវទទួលពិន័យអន្តរការណ៍ចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល និងបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។

ប្រការ៣៩.

ការប្រើប្រាស់អាជ្ញាបណ្ណផុតសុពលភាពត្រូវទទួលពិន័យអន្តរការណ៍ចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល និងត្រូវរួសរាន់ដាក់ពាក្យស្នើសុំបន្តសុពលភាពក្នុងករណីមិនរាងចាលក្រសួងនឹងចាត់វិធានការបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ។

ការប្រើប្រាស់លិខិតអនុញ្ញាតប្រកបអាជីវកម្មផុតសុពលភាពត្រូវទទួលពិន័យអន្តរការណ៍ចំនួន ២.៥០០.០០០ (ពីរលានប្រាំរយពាន់) រៀល និងត្រូវរួសរាន់ដាក់ពាក្យស្នើសុំបន្តសុពលភាពក្នុងករណីមិនរាងចាលមន្ទីរនឹងចាត់វិធានការបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ។

ប្រការ៤០.

ការប្រកបអាជីវកម្មខុសពីទីតាំងដែលបានបញ្ជាក់នៅលើអាជ្ញាបណ្ណត្រូវទទួលពិន័យអន្តរការណ៍ចំនួន ២.០០០.០០០ (ពីរលាន)រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

ការប្រកបអាជីវកម្មខុសពីទីតាំងដែលបានបញ្ជាក់នៅលើលិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវទទួលពិន័យអន្តរការណ៍ចំនួន ១.០០០.០០០ (មួយលាន) រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

ប្រការ៤១.

ការផ្តល់ប្រាក់កម្ចីលើសពីដើមទុនដែលបានប្រកាសជាមួយក្រសួងត្រូវទទួលពិន័យអន្តរការណ៍ចំនួន ៣.០០០.០០០ (បីលាន) រៀល។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការព្យួរអាជ្ញាបណ្ណបណ្តោះអាសន្ន។

ការផ្តល់ប្រាក់កម្ចីលើសពីដើមទុនដែលបានប្រកាសជាមួយមន្ទីរត្រូវទទួលពិន័យអន្តរការណ៍ចំនួន១.៥០០.០០០ (មួយលានប្រាំរយពាន់) រៀល។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការព្យួរអាជ្ញាបណ្ណបណ្តោះអាសន្ន។

ប្រការ៤២.

ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំបង់ថ្លៃបន្តសុពលភាពអាជ្ញាបណ្ណប្រចាំឆ្នាំដូចមានចែងក្នុងប្រការ១០ ត្រូវទទួលពិន័យអន្តរការណ៍ចំនួន២០.០០០ (ម្ភៃពាន់) រៀល ក្នុង ០១ ថ្ងៃសម្រាប់រយៈពេលពាក់ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាលចំនួនទឹកប្រាក់ជាកពិន័យត្រូវគុណទ្វេដង។

ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតប្រកបអាជីវកម្មក្នុងរយៈពេលពាក់ថ្ងៃមុន លិខិតអនុញ្ញាតប្រកបអាជីវកម្មផុតសុពលភាពត្រូវទទួលពិន័យអន្តរការណ៍ចំនួន១០.០០០ (ដប់ពាន់)រៀល ក្នុង០១ថ្ងៃសម្រាប់រយៈពេលពាក់ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍ត្រូវគុណទ្វេដង។

ប្រការ៤៣.

ការបង្កើតសាខាដោយគ្មានអាជ្ញាបណ្ណពីក្រសួងត្រូវទទួលពិន័យអន្តរការណ៍ចំនួន ៣.០០០.០០០ (បីលាន) រៀលក្នុង០១សាខា និងត្រូវផ្អាកសកម្មភាពអាជីវកម្មសាខា។ ដើម្បីអាចបន្តសកម្មភាពអាជីវកម្មបាន ក្រុមហ៊ុន/សហគ្រាស ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណសាខានោះ។ ក្នុងករណីមិនរាងចាលក្រសួងនឹងព្យួរឬដកហូតអាជ្ញាបណ្ណក្រុមហ៊ុន/សហគ្រាសមេ។

ការបង្កើតសាខាដោយគ្មានលិខិតអនុញ្ញាតប្រកបអាជីវកម្មពីមន្ទីរត្រូវទទួលពិន័យអន្តរការណ៍ចំនួន ១.៥០០.០០០ (មួយលានប្រាំរយពាន់) រៀលក្នុង០១ សាខា និងត្រូវផ្អាកសកម្មភាពអាជីវកម្មសាខា។ ដើម្បីអាចបន្តសកម្មភាពអាជីវកម្មបានក្រុមហ៊ុន/សហគ្រាស ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសម្រាប់សាខានោះ។ ក្នុងករណីមិនរាងចាលមន្ទីរនឹងព្យួរ ឬដកហូតលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមហ៊ុន/សហគ្រាសមេ។

ប្រការ៤៤.

ការធ្វើអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណត្រូវទទួលពិន័យអន្តរការណ៍ចំនួន២.០០០.០០០ (ពីរលាន) រៀលក្នុង០១ករណី និងផ្អាកអាជីវកម្មនោះជាបន្ទាន់។ ក្នុងករណីមិនរាងចាលក្រសួងនឹងព្យួរ ឬដកហូតអាជ្ញាបណ្ណនោះ។

ការធ្វើអាជីវកម្មខុសពីកម្មវត្ថុនៃលិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវទទួលពិន័យអន្តរការណ៍ចំនួន១.០០០.០០០ (មួយលាន) រៀលក្នុង០១ ករណី និងផ្អាកអាជីវកម្មនោះជាបន្ទាន់។ ក្នុងករណីមិនរាងចាលមន្ទីរនឹងព្យួរ ឬដកហូតលិខិតអនុញ្ញាតប្រកបអាជីវកម្មនោះ។

ប្រការ៤៥.

ក្រោយពីទទួលលិខិតព្រមានជាលាយលក្ខណ៍អក្សរ អ្នកកាន់អាជ្ញាបណ្ណនៅតែប្រព្រឹត្តផ្ទុយនឹងចំណុចណាមួយនៃប្រការ១៣ និងប្រការ១៤ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន៤០០.០០០ (បួនរយពាន់) រៀលក្នុង០១ ករណី។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការដកហូត ឬបញ្ឈប់សកម្មអាជីកម្ម។

ក្រោយពីទទួលលិខិតព្រមានជាលាយលក្ខណ៍អក្សរ ហើយអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មនៅតែប្រព្រឹត្តផ្ទុយនឹងចំណុចណាមួយនៃប្រការ១៣ និងប្រការ១៤ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ពីមន្ទីរចំនួន២០០.០០០ (ពីររយពាន់)រៀលក្នុង០១ ករណី។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការដកហូត ឬបញ្ឈប់សកម្មអាជីកម្ម។

ប្រការ៤៦.

អ្នកកាន់អាជ្ញាបណ្ណទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងប្រការ១៥ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន ២.០០០.០០០ (ពីរលាន) រៀលក្នុង០១ ករណី។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងប្រការ១៥ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន១.០០០.០០០ (មួយលាន) រៀលក្នុង០១ ករណី។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

ប្រការ៤៧.

អ្នកកាន់អាជ្ញាបណ្ណទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងប្រការ២០ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន ១.០០០.០០០ (មួយលាន) រៀលក្នុង០១ ករណី និងត្រូវផ្អាកសកម្មភាពអាជីវកម្មជាបន្ទាន់ហើយត្រូវបំពេញឯកសារស្នើសុំ។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងប្រការ២០ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន៥០០.០០០ (ប្រាំរយពាន់) រៀលក្នុង០១ ករណី និងត្រូវផ្អាកសកម្មភាពអាជីវកម្មជាបន្ទាន់។ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

ប្រការ៤៨.-

អ្នកកាន់អាជ្ញាបណ្ណទាំងឡាយណាដែលផ្តល់របាយការណ៍យឺតយ៉ាវដូចមានចែងក្នុងប្រការ២៩ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន២០.០០០ (ម្ភៃពាន់) រៀលក្នុង០១ (មួយ) ថ្ងៃសម្រាប់រយៈពេល៣០ ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការព្យួរ ឬដកហូតអាជ្ញាបណ្ណ។

អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មទាំងឡាយណាដែលផ្តល់របាយការណ៍យឺតយ៉ាវ ដូចមានចែងក្នុងប្រការ២៩ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន១០.០០០ (ដប់ពាន់) រៀល ក្នុង០១ (មួយ) ថ្ងៃសម្រាប់រយៈពេល៣០ ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការព្យួរ ឬដកហូតលិខិតអនុញ្ញាតប្រកបអាជីវកម្ម។

ជំពូកទី០៩
អន្តរប្បញ្ញត្តិ

ប្រការ៤៩.-

អាជ្ញាបណ្ណទទួលបញ្ចាំ និង/ឬទទួលប្រាតិភោគដោយអនុប្បទានដែលក្រសួងផ្តល់ជូនមុនពេលដាក់ឱ្យអនុវត្តប្រកាសនេះនៅបន្តមានសុពលភាពរហូតដល់ផុតកាលកំណត់សុពលភាពរបស់អាជ្ញាបណ្ណនោះ។

ជំពូកទី១០
អវសានប្បញ្ញត្តិ

ប្រការ៥០.-

ប្រកាសលេខ០២៨សហវ.ប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១០ ស្តីពីការផ្តល់អាជ្ញាបណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

ប្រការ៥១.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្រុមហ៊ុន/សហគ្រាស និងបុគ្គលដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ ២០១៧ តទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៧

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- ធនាគារជាតិនៃកម្ពុជា
- សាលារាជធានី-ខេត្ត
- ដូចប្រការ៥១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រក្សាសិទ្ធ និងបោះពុម្ពដោយ
អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
នៃ ទីស្តីការគណៈរដ្ឋមន្ត្រី